ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ព្រះឆាយាល័ក្ខណ៍ដ៏កម្ររបស់ ព្រះករុណា ព្រះបាទសម្ដេចព្រះ បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា កាលវ័យកុមារ
- គណៈប្រតិភូស្ត្រីដែលតំណាងឱ្យកម្ពុជា ចិន ប្រ៊ុយណេ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ជប៉ុន និងកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្ដីសុបិនកម្ពុជា»

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧៥ ខែវិច្ឆិកា ឆ្នាំ២០២២

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧៥ ខែវិច្ឆិកា ឆ្នាំ២០២២



សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


◆ ព្រះឆាយាលក្ខណ៍ដឹកម្ររបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ.................. ១
◆ ផ្កាសំបួរមុខមាត់បុគ្គល សហគមន៍.......... ៣


### ផ្នែកឯកសារ


◆ នៃ រស់ ហៅ យី ៖ អនុក្រុមបង្កើនផល ...... ៦


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ សហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត .... ៩
◆ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យកម្ពុជា ចិន ប្រ៊ុយណេ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ជប៉ុន........ ១១
◆ សហប្រធានអង្គការវេទិកាប្រវត្តិសាស្ត្រសម្រាប់សន្តិភាព អាស៊ីខាងកើតទស្សនកិច្ច....... ១៤
◆ ស្ត្រីទីមួយនៃបណ្តាប្រទេសអាស៊ានទស្សនកិច្ចបណ្ណាល័យ សម្តេចម៉ែ នៃមជ្ឈមណ្ឌល .... ១៦
◆ ក្រុមការងាររគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះសួរសុខទុក្ខ និងចែក .. ១៨
◆ វង់ វិន ៖ ខ្មែរក្រហមឃោសនាថា «ខ្មែរ..... ២២
◆ គង់ គីង ៖ ខ្ញុំកើតកូននៅតាមផ្លូវ តែ...... ២៤
◆ គិន ម៉ីន ៖ ខ្ញុំចូលកងទ័ពតាមការឃោសនា..២៦
◆ ជា សុខន ៖ សុខចិត្តធ្វើជាមនុស្សឆ្កួត .... ២៨
◆ ជុំ ហាច ៖ បងរបស់ខ្ញុំ ៤ នាក់ ត្រូវខ្មែរ ... ៣១
◆ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាប់យក ..... ៣៣
◆ តក់ ធុន ៖ ទាស់សរសៃដោយសារ........ ៣៥
◆ ប៉ា សុខន ៖ កងចល័តនារី.................. ៣៧
◆ ប៊ុន វ៉ាត ៖ ឪពុកម្តាយខ្ញុំស្លាប់ដោយសារ. ៣៩
◆ ប៉ុល ស៊ីម ៖ អតីតគ្រូបង្រៀន .............. ៤១
◆ ជាសះស្បើយពីជំងឺដោយសារលេប...... ៤៣
◆ ដោយសារខ្វះខាតអាហារ ម្តាយខ្ញុំ........ ៤៥
◆ ផុន ជុំ ៖ កងចល័តក្នុងរបបខ្មែរក្រហម .. ៤៧
◆ យង់ សាលូត ៖ កងដឹកប្រឡាយនៅ ..... ៤៩


### ផ្នែក វេទិកាពិភាក្សាសាធារណៈ


◆ វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រ....... ៥២
◆ ប្រតិភូមកពីក្រសួងការពារជាតិទស្សនកិច្ចពិព័រណ៍ «សុបិនកម្ពុជា» ..................... ៥៥


### ផ្នែកស្រាវជ្រាវរកក្រួសារ


◆ សូមប្រកាសរកសមាជិកគ្រួសារ......... ៥៩



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, ដា៉រ៉ាវដ្ឋ មេត្តា, មេក វិន, សោម ប៊ុនថន, ដាត ចាន់សុនិតា, រីម ស្រីស្រស់, វី ស៊ីថា, ថុន ស្រីពេជ្រ, ហ៊ាន ពិសី, សៀង កញ្ញា, ទូច វណ្ណេត, ឈុំ វ៉ា, សូ ហាន់, ង៉ាន់ វិន និង ភារស្មី

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដា៉រ៉ាវដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ព្រះឆាយាល័ក្ខណ៍ដ៏កម្ររបស់ ព្រះករុណា

## ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា កាលវ័យកុមារ

**ឆាំង យុ**




*ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ចាប់ដៃប្រធានាធិបតីប្រទេសឆេកូស្លូវ៉ាគី លោក Antonin Novotny ប្រហែលជានៅឆ្នាំ១៩៦៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ព្រះឆាយាល័ក្ខណ៍ ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនីជាមួយប្រធានាធិបតីប្រទេសឆេកូស្លូវ៉ាគី លោក Antonin Novotny ប្រហែលជានៅឆ្នាំ១៩៦៣។ ព្រះឆាយាល័ក្ខណ៍របស់ទ្រង់ថតដោយ Jiri Rublic ត្រូវបានដាក់តាំងបង្ហាញនៅក្នុង «ពិព័រណ៍ក្តីសុបិនកម្ពុជា» នៅសាល

មហោស្រពចតុមុខដែលរៀបចំឡើងដោយបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ព្រះឆាយាល័ក្ខណ៍នេះ បានឆ្លុះបញ្ចាំងអំពីអតីតកាលដែលមិនចេះនឿយណាយ និងទទួលបានការសព្វព្រះរាជហឫទ័យពីព្រះរាជវង្សានុវង្ស។

«ពិព័រណ៍ក្តីសុបិនកម្ពុជា» ត្រូវបានរៀបចំឡើងដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការណែនាំពី សម្តេច រាជបុត្រី ព្រះអនុជ នរោត្តម អរុណរស្មី ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាព្រះស្ថាបនិកមូលនិធិមុទិតា និង ឯកឧត្តម ហ៊ុន ម៉ានី ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ក្នុងឱកាសគម្រប់ខួប១០០ព្រះវស្សានៃការយាងចូលទិវង្គតរបស់ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ។ ដោយមានការអនុញ្ញាតពីព្រះរាជវង្សានុវង្ស មជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តរក្សាការតាំងពិព័រណ៍ដ៏ប្រណិតនេះ សម្រាប់កិច្ចប្រជុំកំពូលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) លើកទី៤០ និងទី៤១ និងកិច្ចប្រជុំពាក់ព័ន្ធនានា។




ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ជួបជាមួយប្រធានាធិបតីប្រទេសឆេកូស្លូវ៉ាគី លោក Antonin Novotny ប្រហែលជានៅឆ្នាំ១៩៦៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផ្លាស់ប្តូរមុខមាត់បុគ្គល សហគមន៍ និងប្រជាជន តាមរយៈការអប់រំ

**ឆាំង យុ**



ស្ត្រីទីមួយនៃបណ្តាប្រទេសអាស៊ានទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីអ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ ដែលជ្រេសអតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ។
( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

***សម្តេចព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនិនាថ សីហនុ*** ត្រូវបានទទួលស្គាល់ថាជាថ្នាក់ដឹកនាំមួយអង្គ ជាព្រះរាជមគ្គុទ្ទេសក៍នាំផ្លូវ និងជាព្រះនិមិត្តរូបតំណាងឲ្យកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការផ្លាស់ប្តូរមុខមាត់ថ្មីរបស់ប្រជាជនកម្ពុជា តាមរយៈការអប់រំ។ ដើម្បីជាការទទួលស្គាល់ចំពោះកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដ៏វិសេសវិសាលនៃសម្តេចព្រះវររាជមាតាជាតិខ្មែរ មជ្ឈមណ្ឌលឯកសាកម្ពុជា មានកិត្តិយសបង្កើតជា បណ្ណាល័យសម្តេចម៉ែ ដែលដើរតួនាទីជាស្ថាប័នមួយ គាំពារដល់ការអប់រំ, ការសិក្សាស្រាវជ្រាវ និងការអភិរក្សប្រវត្តិសាស្រ្តកម្ពុជា។

បើកសម្ពោធជាផ្លូវការនាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ បណ្ណាល័យសម្តេចម៉ែ តម្កល់សៀវភៅរាប់ពាន់ក្បាល រួមជាមួយនឹងឯកសារនិងវត្ថុសិល្បៈ និងប្រវត្តិសាស្រ្តមិនអាចកាត់ថ្លៃបានជាច្រើនស្តីអំពីប្រវត្តិសាស្រ្តកម្ពុជា។ បណ្តុំឯកសារដែលតម្កល់ទុក



ស្ត្រីទីមួយនៃបណ្ដាប្រទេសអាស៊ានទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីអ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រើសអតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្ដេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ។
( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )







បណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។
( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅក្នុងបណ្ណាល័យ រួមមាន បណ្ណសារឯកសារខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលគួបផ្សំនូវឯកសារប្រមាណជាង១លាន៧សែនទំព័រ ស្តីពីរបបខ្មែរក្រហម ក៏ដូចជាឯកសារសោទស្សន៍ដែលជាបទសម្ភាសន៍កត់ត្រាទុកនូវបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែមទៀតផង។ បន្ថែមលើសពីនេះទៅទៀត បណ្ណាល័យក៏មានតម្កល់ទុកសៀវភៅ, ឯកសារជាក្រដាស, ឯកសារសោទស្សន៍ និងសម្ភារនានាស្តីពីព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ។ ឯកសារទាំងអស់នេះ ត្រូវបានប្រមែប្រមូលចងក្រងដោយឯកអគ្គរាជទូត ហ្សូលីយ៉ូ អេ. ហែលជ្រេស ក្នុងអំឡុងពេលដែលលោកសិក្សាស្រាវជ្រាវចងក្រងឯកសារស្តីពីសែស្រឡាយរាជវង្ស និងប្រវត្តិសាស្រ្តប្រទេសកម្ពុជា។ ជាចុងបញ្ចប់ បណ្ណាល័យសម្តេចម៉ែ មានតាំងបង្ហាញនូវពិព័រណ៍រូបភាពប្លង់ស្ថាបត្យកម្មនៃវិទ្យាស្ថានស្លឹករឹត។ វិទ្យាស្ថានស្លឹករឹត គឺជាចក្ខុវិស័យរបស់លោក ឆាំង យុ ដែលនឹងជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយនឹងមានរួមបញ្ចូលនូវសារមន្ទីរ, មជ្ឈមណ្ឌលស្រាវជ្រាវ, សាកលវិទ្យាល័យ, បណ្ណាល័យ និងបណ្ណសារដ្ឋាន។ វិទ្យាស្ថានស្លឹករឹតគឺជាស្នាដៃរចនារបស់ស្ថាបត្យករដ៏ល្បីល្បាញ លោកស្រី ហ្សាហា ហាឌីដ។






បណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។
(លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្ណាល័យសម្តេចម៉ែ គាំទ្រយ៉ាងមុតមាំចំពោះការយល់ឃើញថា ការអប់រំគឺជាការផ្សាស្បូវមុខមាត់ថ្មី។ ការអប់រំផ្តល់នូវឱកាសមួយ ឈានទៅសម្រេចការផ្សាស្បូវ និងផ្តល់សេរីភាពដល់បុគ្គល, សហគមន៍ និងប្រជាជាតិ។ ការអប់រំ អាចបញ្ឈប់ការកកើតឡើងវិញនៃអំពើហិង្សា, ភាពអមនុស្សធម៌ និងការគាបសង្កត់នៅក្នុងប្រវត្តិសាស្រ្ត។ ទន្ទឹមនឹងនេះដែរ ការអប់រំអាចផ្តល់ជាឱកាសមួយ ដើម្បីនឹករំពៃជាថ្មីក្នុងការបង្កើតជាអនាគតថ្មីមួយ។

យើងខ្ញុំពិតជាមានកិត្តិយសយ៉ាងអនេក ដែលលោកជំទាវ អញ្ជើញទស្សនកិច្ចមកកាន់បណ្ណាល័យសម្តេចម៉ែនៅក្នុងថ្ងៃនេះ។ យើងខ្ញុំរីករាយក្នុងការឆ្លើយតបនូវរាល់សំណួរ និងមតិយោបល់ចំពោះបណ្ណាល័យសម្តេចម៉ែ និងការងាររបស់យើងខ្ញុំ។

# នៃ រស់ ហៅ យី ៖ អនុក្រុមបង្កើនផលសិល្បៈឃោសនាការ

ដារ៉ាវ៉ុន្ត មេត្តា



ការសម្តែងសិល្បៈរបស់កងសិល្បៈបដិវត្តន៍ខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នៃ រស់ ហៅ យី ភេទប្រុស អាយុ២៧ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំមានស្រុកកំណើតនៅភូមិមុះធំ ឃុំប្រមេ (ប្រមេរុ) ស្រុកវីរភាព (បច្ចុប្បន្នស្រុកត្បែងមានជ័យ) តំបន់១០៣ ខេត្តព្រះវិហារ។ ខ្ញុំមានប្រពន្ធឈ្មោះ ប៉ែន ស៊ីនួន ហៅ វ៉ាន ធ្វើការនៅមន្ទីរក-៣២។ នៅឆ្នាំ១៩៦៩ ខ្ញុំចូលរៀននៅសាលាស្ថិតនៅក្នុងភូមិពោធិ៍ ឃុំប្រមេ ស្រុកវីរភាព ដល់ត្រឹមថ្នាក់ទី១០។ នៅឆ្នាំ១៩៧០ ខ្ញុំឈប់រៀន ហើយរស់នៅជាមួយម្តាយឪពុក។ នៅក្នុងឆ្នាំ១៩៧១ ខ្ញុំចូលបដិវត្តន៍នៅមន្ទីរឃោសនាការអប់រំភូមិពោធិ៍ ឃុំប្រមេ ស្រុកវីរភាព តំបន់១០៣។ នៅក្នុងឆ្នាំ១៩៧២ ខ្ញុំមករស់នៅក្នុងមន្ទីរប-១៨ និងមានតួនាទីដឹកជញ្ជូនអង្ករ និងគ្រាប់បែកពីព្រះវិហារចូលមកមន្ទីរប-១៨ សម្រាប់ផ្តល់ទៅឲ្យកងទ័ពនៅសមរភូមិមុខ។ នៅចុងឆ្នាំ១៩៧២ ខ្ញុំមកនៅមន្ទីរបង្កបង្កើនផល ប្រុប-១៧ វិញ។

នៅឆ្នាំ១៩៧៣ ខ្ញុំផ្លាស់មកនៅមន្ទីរស-៦ ផ្នែកសិល្បៈ។ ពេលនោះខ្ញុំបានជួបឈ្មោះ ទ្រា ហៅ

សៅ គឺជាប្រធានមន្ទីរស-៦។ ខ្ញុំប្រាស្រ័យទាក់ទងជាមួយ សៅ យ៉ាងជិតស្និទ្ធហើយគាត់បានអូទាញខ្ញុំជាបន្តបន្ទាប់។ ក្រោយមកខ្ញុំចូលជា សេ-អ៊ី-អា តាមការអប់រំរបស់ សៅ នៅមន្ទីរស-៦ ដោយមានអ្នកខ្ទេសនាមឈ្មោះ ភិន គឺជាអនុប្រធានឃោសនាការ, ឈ្មោះ ហូ នឹម ហៅ ភាស់ គឺជាប្រធានឃោសនាការ។ ក្រោយមកបង សៅ ចាត់តាំងខ្ញុំឲ្យអប់រំយុទ្ធជន-យុទ្ធនារី ដោយពន្យល់ហេតុផលអ្នកទាំងនោះឲ្យឃើញច្បាស់អំពីការលំបាកពេលធ្វើបដិវត្តន៍, បំផ្លាញគ្រឿងម៉ាស៊ីន និងបំផុសទំនាស់នៅក្នុងមន្ទីរ។

នៅចុងឆ្នាំ១៩៧៣ បងភាស់, បងភិន, បងសៅ បានហៅខ្ញុំ, ហ៊ាង មានតួនាទីជាគណៈពាក់ព័ន្ធអត្ថាធិប្បាយវិទ្យុ, យិន មានតួនាទីជាគណៈច្នៃរបាំ និង សា មានតួនាទីជាគណៈពាក់ព័ន្ធចម្រៀងសិល្បៈឲ្យទៅប្រជុំនៅមន្ទីរស-៦ ដោយដាក់ផែនការ ១) អប់រំយុទ្ធជនយុទ្ធនារីនៅក្នុងមន្ទីរឲ្យទំនាស់នឹងអង្គការបដិវត្តន៍ និងត្រូវអប់រំយុទ្ធជនឲ្យឃើញពីទុក្ខវេទនានៅក្នុងបដិវត្តន៍ ២) ត្រូវបំផ្លាញម៉ាស៊ីនថត និងសម្ភារផ្សេងៗដែលទុកនៅក្នុងឃ្លាំងឲ្យខូច ទី៣) ត្រូវរកវិធីសម្លាប់អង្គការ នួន ជា នៅតាមកន្លែងសម្តែងសិល្បៈដោយវិធីបាញ់នឹងកាំភ្លើង ប្លុំបោលគ្រាប់បែក ក្រៅពីនេះត្រូវដាក់ថ្នាំពុលនៅក្នុងទឹកក្តៅប្លុំបន្តប់នៅក្នុងបន្លែមផ្លែឈើ ដូចជា ចេកទុំ ខ្នុរ ល្មុត និងស្វាយ។

នៅឆ្នាំ១៩៧៤ ខ្ញុំ, ហ៊ាង, យិន, សា, សៅ ចូលរួមធ្វើសកម្មភាពតាមផែនការទី១ ដែលបងភាស់ និងបងភិន ឲ្យយើងអប់រំយុទ្ធជន-យុទ្ធនារី។ នៅក្នុងមន្ទីរ យើងបានឯកភាពគ្នាអប់រំបានឈ្មោះ សុង គឺជាយុទ្ធជនក្រុមភ្លេង, បូ ជា គឺជាប្រធានក្រុមភ្លេង, ខឿន គឺជាយុទ្ធជនវាយអង្គុលីលេខ។

នៅចុងឆ្នាំ១៩៧៤ យើងធ្វើសកម្មភាពរារាំងចលនាវាយសម្រុកបង្កបង្កើនផលរបស់មហាជននៅក្នុងមន្ទីរដោយអប់រំកុំឲ្យយុទ្ធជនវាយសម្រុកខ្លាំងពេកទុកពេលទំនេរឲ្យច្រើនដាំដុះដំណាំតិចតួចបានហើយ។

នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំ, សាយ, យិនកសាងកម្លាំងបានចំនួន៣នាក់ទៀត រួមមាន ហ៊ាង គឺជាសមាជិកគណៈពាក់ព័ន្ធ, រុន គឺជានារីផ្នែកចម្រៀងមន្ទីរឃោសនាការ, ឡួន គឺជាយុទ្ធជនមន្ទីរឃោសនាការ។

នៅចុងឆ្នាំ១៩៧៥ បងភាស់ និងបងភិន ហៅខ្ញុំទៅប្រជុំនៅឃោសនាការស្ថិតនៅសាលាដេកាតបន្ទប់ក្រោមៗ អ្នកចូលរួមប្រជុំមាន ខ្ញុំ, យិន, ហ៊ាង, សា, សុង និង ចេង។ នៅក្នុងខ្ទឹមសារប្រជុំមានបងភាស់ខ្ទេសនាមឲ្យស្គាល់ខ្សែគិញមាន សាត គឺជាគណៈច្នៃរបាំ, អឿន គឺជាយុទ្ធនារីនៅមន្ទីរក-៣២, ហ៊ុន គឺជាប្រធានជួសជុលវិទ្យុ។ ការប្រជុំលើកឡើងអំពីផែនការដែលមិនទាន់រកវិធីដោះស្រាយបានគឺផែនការសម្លាប់បងៗ និងកម្លាំងបដិវត្តន៍នៅថ្ងៃបុណ្យជាតិ និងពេលសម្តែងតែម្តងៗ។ ក្រោយមកខ្ញុំផ្តល់មតិថា មានតែគ្រាប់បែកទេទើបអាចនាំចូលបានគឺយើងត្រូវដាក់នៅក្រោមពូក ឡានក្រុមសិល្បៈ ហើយកងទ័ពមិនសូវចាប់អារម្មណ៍ទេ។ បងភាស់ ចាត់តាំងកម្លាំងត្រៀមជាស្រេចបន្ទាប់ពីគាត់បានយល់ស្របលើគំនិតរបស់ខ្ញុំ។ យើងបានចាត់តាំង យិន និង សុង ឲ្យទទួលខាងភ្លើង, ហ៊ាង និង ចេង ឲ្យទទួលខាងគ្រាប់បែក, ខ្ញុំនិងបងសៅ ទទួលខាងពិនិត្យសភាពការណ៍ពេលណាអាចអនុវត្តបាន គឺត្រូវឲ្យជាសញ្ញាភ្លើង ដោយយើងសម្រេចថាមុននឹងបោកគ្រាប់បែកត្រូវផ្តាច់ភ្លើងជាមុន។

នៅឆ្នាំ១៩៧៧ មុនពេលបុណ្យជាតិ យើងមានការផ្លាស់ប្តូរកម្លាំងខ្លះនិងបានចាត់តាំងភារកិច្ចរួចរាល់រួមមាន យិន, ហ៊ាង, បូ, សុង និង សំ ទទួលខាងគ្រាប់បែក។ ហ៊ុន និង សែន មានតួនាទី ជាប្រធានធ្វើជីនិង សៀន គឺជាយុទ្ធជនជួសជុលវិទ្យុ ទទួលខាងផ្តាច់ភ្លើង ហើយខ្ញុំ, បងសៅ ,បងសុង ទទួលពិនិត្យសភាពការណ៍នៅពេលបុណ្យ គឺពេលណាត្រូវធ្វើសកម្មភាពនិងពេលណាមិនត្រូវធ្វើសកម្មភាព។ នៅឆ្នាំ១៩៧៧ ដដែល ខ្ញុំ, សំ, សែន បានឯកភាពគ្នាធ្វើសកម្មភាពដោយយកខ្សែភ្លើងដោតឲ្យឆេះវិទ្យុ។ ក្រោយមកទៀតខ្ញុំ, បូ, ស៊ិន គឺជាគណៈរបាំសិល្បៈ,

ហ៊ានបានលាក់ទឹកក្រូចចំនួន១៥ ឡាំង ដែលអង្គការជូនសម្រាប់បំប៉នយុទ្ធជនសិល្បៈ។ ពេលនោះខ្ញុំបានចាក់សោរឃ្លាំងធ្វើឲ្យខូចទឹកក្រូចអស់។ បន្ទាប់មកយើងទាំង៦នាក់បាននាំគ្នាសែងទឹកក្រូចយកទៅចាក់ចោលនៅវេលាម៉ោង១២យប់ ដោយមិនឲ្យអ្នកណាដឹងឡើយ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ខ្ញុំ, សំ, និង ម៉ន គឺជាគណៈពាក់ព័ន្ធអគ្គាធិប្បាយវិទ្យុ នាំគ្នាលាក់ខោអាវយុទ្ធជនចំនួន១០០សម្រាប់ និងសំពត់-អាវសម្រាប់យុទ្ធនារី១០០សម្រាប់។ ពេលនោះខ្ញុំដាក់ក្នុងហិបហើយចាក់សោ ទុកក្នុងឃ្លាំង ក្រោយមកខោអាវនោះពុកផុយខូចអស់ហើយ នាំគ្នាដុតចោលថែមទៀត ធ្វើឲ្យយុវជនខ្វះខាតគ្មានខោអាវផ្លាស់ប្ដូរ។ ទោះបីជាអង្គការផ្ដល់ឲ្យគ្រប់គ្រាន់ក៏ដោយ ក៏យើងទាំង៣នាក់បានបំផ្លាញទាំងអស់ដែរ។ បន្ទាប់មក បងភាស់ បានណែនាំឲ្យទៅលីក្រណាត់ក្នុងឃ្លាំងចំនួន២០គី ដែលស្នើអង្គការក្នុងគោលបំណងធ្វើជាវាំងននសិល្បៈ ទោះបីវាំងននមានគ្រប់គ្រាន់ហើយក៏ដោយ។ អ្នកចូលរួមមាន ចេង គឺជាយុទ្ធជនថតរូបនៅមន្ទីរភាពយន្ត, ស៊ី, ស៊ីន, ហេង គឺជាយុទ្ធជនក្នុងក្រុមភ្លេង, សៀន, សំ គឺជាប្រធានមន្ទីរគ-៣៣ ឃោសនាការ។ ក្រៅពីនេះ ខ្ញុំ,ចេង, សំ បានធ្វើសកម្មភាពលាក់ខ្សែអាត់ ៣០០ដុំ សម្រាប់ចម្លងជូនអង្គការពិនិត្យ ដោយយើងបានចាក់សោរចោលក្នុងឃ្លាំងមិនឲ្យប្រើប្រាស់រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ ពេលដែលអង្គការចាប់ខ្លួនបងភាស់ និងបងសៅ។ បន្ទាប់មកអង្គការចាប់ខ្សែទាក់ទងនឹងបងសៅ ជាបន្តបន្ទាប់រហូតដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្ញុំតែម្ដង។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០១៧២។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ នៃ រស់ ហៅ យី ពិតឬយ៉ាងណានោះទេ?**



កងសិល្បៈបដិវត្តន៍ខ្មែរក្រហម ថតជុំគ្នានៅប្រាសាទបន្ទាយស្រី ក្នុងខេត្តសៀមរាប។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត

## ទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

***មេក ទិន***




សាស្ត្រាចារ្យ សុងហូ កាង គឺជាសហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត នៃប្រទេសកូរ៉េខាងត្បូង និងសហការីធ្វើដំណើរទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដោយមានការទទួលស្វាគមន៍ពីបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍ សាស្ត្រាចារ្យ សុងហូ កាង គឺជាសហប្រធានវេទិកាប្រវត្តិសាស្ត្រអង្គការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត នៃប្រទេសកូរ៉េខាងត្បូង បានធ្វើដំណើរមកទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ លោកសាស្ត្រាចារ្យមានការចំណាប់អារម្មណ៍ និងចង់ឈ្វេងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីងាយស្រួលក្នុងការដឹកនាំសិស្ស និងនិស្សិតមកពីប្រទេសកូរ៉េខាងត្បូងមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

រួមដំណើរជាមួយសហការីជនជាតិកូរ៉េខាងត្បូង សាស្ត្រាចារ្យ សុងហូ កាង បានធ្វើដំណើរមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២។ បច្ចុប្បន្ននេះ អន្លង់វែង គឺជាស្រុកមួយដ៏មានសក្តានុពលលើផ្នែកសេដ្ឋកិច្ច និងផ្នែកទេសចរណ៍ក្នុងខេត្តឧត្តរមានជ័យ។ លើសពីនេះទៅទៀត តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ចំនួន១៤អាចផ្តល់នូវចំណេះដឹង និងបទពិសោធន៍ដល់អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ។ មិនត្រឹមតែប៉ុណ្ណោះ



សាស្ត្រាចារ្យ សុង ហូ កាង គឺជាសហប្រធានវេទិកាប្រវត្តិសាស្ត្រអន្តរការក្រៅរដ្ឋាភិបាលប្រចាំនៅតំបន់អាស៊ីខាងកើត នៃប្រទេសកូរ៉េខាងត្បូង និងសហការីធ្វើដំណើរមកទស្សនកិច្ចតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដោយមានការទទួលស្វាគមន៍ពីបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







តំបន់ប្រវត្តិសាស្ត្រអន្លង់វែងបានផ្សារភ្ជាប់ទៅនឹងប្រវត្តិសាស្ត្រយោធា ដែលធ្វើឲ្យតំបន់នេះកាន់តែមានការចាប់អារម្មណ៍ខ្លាំងពីសាធារណជន សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជា ប្រទេសនៅក្នុងអាស៊ាន និងពិភពលោក។ ស្រុកអន្លង់វែង គឺជាទីកន្លែងដែលផ្តល់នូវសន្តិភាព ការផ្សះផ្សា និងការរួមរស់ជាមួយរាជរដ្ឋាភិបាល បន្ទាប់ពីបញ្ចប់សង្គ្រាមរុំារ៉ៃនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។

ក្នុងដំណើរទស្សនកិច្ចនេះ លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានអត្ថាធិប្បាយអំពីគម្រោង និងផែនការនានាទាក់ទងនឹងការបង្រៀនប្រវត្តិសាស្ត្រ ការថែរក្សា និងអភិរក្សតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ឬង់គោលដើម្បីអភិវឌ្ឍន៍ស្រុកអន្លង់វែង និងបានជូនលោកសាស្ត្រាចារ្យទៅសិក្សា និងពិនិត្យមើលទីតាំងប្រវត្តិសាស្ត្រសំខាន់ៗដូចជា សារមន្ទីរផ្ទះតាម៉ុក កន្លែងបូជាសព ប៉ុល ពត និងផ្ទះប្រជុំរបស់តាម៉ុកលើកំពូលភ្នំដងរែក (ដែលបច្ចុប្បន្ននេះគឺជា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង)។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចនេះ លោក សុង ហូ កាង និងសហការី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចំពោះការទទួលស្វាគមន៍ និងការរាក់ទាក់យ៉ាងកក់ក្តៅបំផុត។

# គណៈប្រតិភូស្ត្រីដែលតំណាងឱ្យ
## កម្ពុជា ចិន ប្រ៊ុយណេ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ជប៉ុន និងកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្តីសុបិនកម្ពុជា»

*សោម ប៊ុនថន*



នៅវេលាព្រឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យប្រទេសកម្ពុជា ប្រទេសចិន ប្រទេសប្រ៊ុយណេ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្តីសុបិនកម្ពុជា»។ ( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅវេលាព្រឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យប្រទេសកម្ពុជា ប្រទេសចិន ប្រទេសប្រ៊ុយណេ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្តីសុបិនកម្ពុជា» នៅសាលមហោស្រពចតុមុខ ដែលរៀបចំដោយលោកជំទាវ ដា៉រាវណ្ណ ដារីត លុយ សហការជាមួយបណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ គណៈប្រតិភូដែលជាស្ត្រី ទទួលព្រះរាជស្វាគមន៍យ៉ាងកក់ក្តៅពីសម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មីឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, អ្នកស្រី សូ ហ្សារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត។ ពិព័រណ៍ «សុបិនកម្ពុជា» គឺជាផ្នែកមួយនៃព្រះរាជកម្មវិធី «១០០ព្រះវស្សា នៃព្រះបិតាឯករាជ្យជាតិ» ឧទ្ទិសថ្វាយព្រះបរមរាជវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ។ ពិព័រណ៍ «សុបិនកម្ពុជា»

សម្ពោធនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ក្រោមព្រះរាជធិបតីដ៏ខ្ពង់ខ្ពស់បំផុតពី ព្រះបាទនរោត្តម សីហមុនី និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះញាតិវង្សានុវង្ស ព្រមទាំងឥស្សរជនជាន់ខ្ពស់នៃស្ថាប័នកំពូលៗរបស់ជាតិ។ ពិព័រណ៍នេះទទួលបានការសព្វព្រះរាជហឫទ័យយ៉ាងខ្លាំងពីព្រះមហាក្សត្រខ្មែរ និងរាជវង្សានុវង្ស។

ពិព័រណ៍ «សុបិនកម្ពុជា» បានដាក់តាំងបង្ហាញពីថ្ងៃទី៣១ ខែតុលា ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានទទួលសាធារណជន, គណៈប្រតិភូដែលជាស្ត្រី និងមេដឹកនាំបណ្តាប្រទេសអាស៊ាន និងប្រទេសមួយចំនួនទៀតដែលមកចូលរួមកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤០ និង៤១ និងកិច្ចប្រជុំពាក់ព័ន្ធនានានៅប្រទេស




នៅវេលាព្រឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យប្រទេសកម្ពុជា ប្រទេសចិន ប្រទេសប្រ៊ុយណេ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្តីសុបិនកម្ពុជា»។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅវេលាព្រឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យប្រទេសកម្ពុជា ប្រទេសចិន ប្រទេសប្រ៊ុយណេ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្តីសុបិនកម្ពុជា»។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្ពុជា ចាប់តាំងពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ មានចំនួនសរុបប្រមាណ ៨០០ នាក់។

ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូដែលជាស្ត្រីនៅថ្ងៃនេះ គឺជាដំណើរទស្សនកិច្ចចុងក្រោយដែលបង្ហាញពីការគាំទ្រ និងទទួលស្គាល់ស្នាដៃរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ និងសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រមទាំងបានទាំងបង្ហាញអំពីតួនាទីស្ត្រីក្នុងការចូលរួមនៅក្នុងវិស័យសង្គម វប្បធម៌ សិល្បៈ ប្រវត្តិសាស្ត្រ ការអប់រំ និងនយោបាយ។ នៅក្នុងប្រទេសកម្ពុជាសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ដែលតំណាងឲ្យស្ត្រីខ្មែរទាំងមូល ព្រះអង្គបានជម្នះរាល់ការលំបាក និងឧបសគ្គគ្រប់បែបយ៉ាងតាមដង្ហែព្រះរាជសកម្មភាពជាច្រើនជាមួយនឹងព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ដើម្បីបុព្វហេតុជាតិមាតុភូមិ។ ព្រះអង្គគឺជានិមិត្តរូបនៃភាពរឹងមាំរបស់ស្ត្រីខ្មែរទូទៅ



នៅវេលាព្រឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យប្រទេសកម្ពុជា ប្រទេសចិន ប្រទេសប្រ៊ុយណេ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្ដីសុបិនកម្ពុជា»។ ( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



នៅវេលាព្រឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ គណៈប្រតិភូស្ត្រីដែលតំណាងឲ្យប្រទេសកម្ពុជា ប្រទេសចិន ប្រទេសប្រ៊ុយណេ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង អញ្ជើញមកទស្សនកិច្ចពិព័រណ៍ «ក្ដីសុបិនកម្ពុជា»។ ( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

និងជាម្ហូបសម្រាប់កូនចៅ និងប្រជានុរាស្ត្រខ្មែរ។

គណៈប្រតិភូសម្ដែងការពេញចិត្តនឹងពិព័រណ៍ដែលបានផ្ដល់ការយល់ដឹងអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងរាជវង្សានុវង្សខ្មែរ។ ពិព័រណ៍នេះនឹងផ្ដល់ក្ដីសង្ឃឹមដល់ប្រជាជនកម្ពុជា ដែលបានឆ្លងកាត់ដំណាក់កាលដ៏លំបាកកន្លងមក។ គណៈប្រតិភូក៏សំណូមពរឲ្យបន្តរក្សាពិព័រណ៍«សុបិនកម្ពុជា» សម្រាប់សាធារណជន និងភ្ញៀវទូតចូលទស្សនា។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ច លោក ឆាំង យុ ជូនសៀវភៅសាក្សីប្រវត្តិសាស្ត្ររបស់សម្ដេចព្រះមហាក្សត្រ នរោត្តម សីហនុ, កុនឯកសាររយៈពេល១៤នាទី ដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងព្រះរាជវង្សានុវង្ស និងផ្ទាំងរូបថតរបស់ សម្ដេចព្រះមហាក្សត្រ នរោត្តម សីហនុ ដល់គណៈប្រតិភូ។

# សហប្រធានអង្គការវេទិកាប្រវត្តិសាស្ត្រ សម្រាប់សន្តិភាព អាស៊ីខាងកើត

## ទស្សនកិច្ច «ពិព័រណ៍ក្តីសុបិនកម្ពុជា»

**សោម ប៊ុនថន**



លោក សុងហូ កាង សហប្រធានវេទិកាប្រវត្តិសាស្ត្រសម្រាប់សន្តិភាព អាស៊ីខាងកើត និងជំនួយការ បានមកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ និង «ពិព័រណ៍ក្តីសុបិនកម្ពុជា» ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីដំណើរទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងអតីតតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ, នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ លោក សុងហូ កាង (Sungho Kang) សហប្រធានវេទិកាប្រវត្តិសាស្ត្រសម្រាប់សន្តិភាព អាស៊ីខាងកើត និងជំនួយការ បានមកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ និង «ពិព័រណ៍ក្តីសុបិនកម្ពុជា» ដែលរៀបចំដោយបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសាលមហោស្រពចតុមុខ ដើម្បីឧទ្ទិសថ្វាយព្រះបរមរាជវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរម








វិតនកោដ្ឋគម្រប់ខួបព្រះប្រសូត្រ ១០០ ព្រះវស្សា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត។



លោក សុង ហូ កាង សហប្រធានវេទិកាប្រវត្តិសាស្ត្រ សម្រាប់សន្តិភាព អាស៊ីខាងកើត និងជំនួយការ បានមកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែ និង «ពិព័រណ៍ក្ដីសុបិនកម្ពុជា» ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្ត្រីទីមួយនៃបណ្ដាប្រទេសអាស៊ានទស្សនកិច្ច
## បណ្ណាល័យ សម្ដេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*សោម ប៊ុនថន*



ស្ត្រីទីមួយនៃបណ្ដាប្រទេសអាស៊ានទស្សនកិច្ចបណ្ណាល័យ សម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីអ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រេសអតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្ដេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ។
( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅវេលាម៉ោង ៩៖៤០ នាទីព្រឹក ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ លោកជំទាវ អ៊ីរីណា ប៊ូកូ វីដូដូ ភរិយារបស់ប្រធានាធិបតីឥណ្ឌូនេស៊ី ប៊ូកូ វីដូដូ, លោកជំទាវ ស៊ីចាន់វីផាវ៉ាន់ ភរិយារបស់នាយករដ្ឋមន្ត្រីឡាវ ផនខាំ វីផាវ៉ាន់, លោកជំទាវ លីស អារ៉ាណេតា ម៉ាកូស ភរិយារបស់ប្រធានាធិបតីហ្វីលីពីន ហ្វឺឌីណាន់ម៉ាកូសជូនៀ, លោកជំទាវណារ៉ាផនចាន់អូចា ភរិយារបស់នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចាន់អូចា, លោកជំទាវ ហ៊ីលដឺហ្គាដ វ៉ាប ស្គួល ភរិយារបស់ប្រធានស្ថាប័នវេទិកាសេដ្ឋកិច្ចពិភពលោក, លោកជំទាវ ខេង សំវ៉ាដា ភរិយាឯកឧត្ដម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគណៈប្រតិភូចំនួន១៧រូបទៀត អញ្ជើញមកទស្សនកិច្ចនៅបណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីអ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត

ស្ត្រីទីមួយនៃបណ្តាប្រទេសអាស៊ានទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីអ្នកស្រី សូ ហ្សារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ ដែលជ្រើស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ។
(លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)














និងឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ ដែលជ្រើស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ។

# ក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះសួរសុខទុក្ខ

## និងចែកប្រអប់អនុស្សាវរីយ៍ជូនអ្នករស់រានមានជីវិត ពីរបបខ្មែរក្រហម នៅខេត្តកំពត

ផាត ចាន់សុនិតា



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពត ចូលរួមកម្មវិធីសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី២១ ដល់ ២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមការងារគម្រោង«ការលើកកម្ពស់សិទ្ធិនិងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះសួរសុខទុក្ខ និងជូនប្រអប់អនុស្សាវរីយ៍ចំនួន៦៣០ប្រអប់ រួមមាន អាវយឺត សៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទស្សនាវដ្ដីស្វែងរកការពិត សាប៊ូ នំចុង និងស្ករគ្រាប់ ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៦៣០នាក់ ដែលអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសាកម្ពុជាធ្លាប់ជួបសម្ភាសន៍នៅក្នុងឃុំចំនួន៨ រួមមាន៖ ឃុំនារាយណ៍, ឃុំសត្វពង, ឃុំមានជ័យ, ឃុំត្រមែង, ឃុំម្រោម, ឃុំភ្នំកុង, ឃុំបឹងសាលាខាងជើង និងឃុំដើមដូង។ ឃុំទាំង៨នេះស្ថិតនៅក្នុងស្រុកឈូក, ស្រុកអង្គរជ័យ និង ស្រុកកំពង់ត្រាច ខេត្តកំពត។ ចាប់តាំងពីខែសីហា ឆ្នាំ២០២១ កន្លងមក

អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពត ជំនាន់ទី១, ជំនាន់ទី២, ជំនាន់ទី៣ និងជំនាន់ទី៤ បានចុះសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលត្រូវជាយាយតា, ឪពុកម្តាយ, អ៊ំ, ពូមីង និងអ្នកស្រុកភូមិនៅតាមមូលដ្ឋានរបស់ខ្លួនអំពីបញ្ហាសុខភាព និងសម្ភាសន៍រឿងរ៉ាវជីវិតទាក់ទងបទពិសោធន៍ឆ្លងកាត់សម័យកាលសង្គ្រាម និងក្នុងរបបខ្មែរក្រហមបានចំនួន១៦០០នាក់ ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣៥០០០នាក់ ដែលអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសន៍នៅទូទាំង២៥រាជធានីខេត្តក្រុង។

គោលបំណងនៃគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» គឺ ១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅតាមគោលដៅដែលបានកំណត់ ២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ផ្តល់ជាព័ត៌មាន ក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជននិងសហគមន៍ទាំងនេះ។

អ្នកស្រី គីម សុវណ្ណដានី អ្នកសម្របសម្រួលគម្រោងបានធ្វើបទបង្ហាញទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអំពីអនាម័យក្នុងការរស់នៅស្អាត, ការហូបស្អាត, អាហាររូបបត្ថម្ភសម្រាប់មនុស្សចាស់, ការថែទាំសុខភាពមនុស្សចាស់នៅតាមផ្ទះ, ការលើកទឹកចិត្តគាត់ឲ្យទៅពិនិត្យសុខភាពចៀសវាងសន្និដ្ឋានជំងឺដោយខ្លួនឯង និងពិគ្រោះជាមួយវេជ្ជបណ្ឌិតមុនប្រើប្រាស់ថ្នាំជាដើម។ តាមរយៈទិន្នន័យដែលទទួលបានពីការធ្វើបទសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកន្លងមក មានជំងឺ១០ប្រភេទ ដែលកើតឡើងចំពោះពួកគាត់ក្នុងនោះមានជំងឺ៣ធំៗ តែងតែងកើតមានញឹកញាប់ ដូចជា ១) ជំងឺលើសឈាម, ២) ជំងឺក្រពះពោះវៀន និង ៣) ជំងឺទឹកនោមផ្អែម។ អ្នកស្រី គីម សុវណ្ណដានី បានផ្តល់ជាអនុសាសន៍ក្នុងការបង្ការទប់ស្កាត់ និងរបៀបថែទាំអ្នកជំងឺនៅតាមផ្ទះ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និង សកលវិទ្យាល័យ ស្តេនហ្វត បានសហការគ្នាបង្កើតកូនសៀវភៅ ទាក់ទងជំងឺទាំង១០ប្រភេទ ដែលកើតលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមមាន ទី១) ជំងឺលើសឈាម, ទី២) ជំងឺក្រពះពោះវៀន, ទី៣) ជំងឺគ្រុនចាញ់ ទី៤) ជំងឺផ្លូវចិត្ត, ទី៥) ជំងឺបេះដូង, ទី៦) ជំងឺសន្លាក់, ទី៧) ជំងឺហឺត, ទី៨) ជំងឺទឹកនោមផ្អែម ទី៩) ជំងឺរបេង និង ទី១០) ជំងឺឆ្កួតជ្រូក។

**លោក ស្រី អាន់** អាយុ៥៦ឆ្នាំ មេឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត មានប្រសាសន៍នៅក្នុងកម្មវិធីចែកប្រអប់អនុស្សាវរីយ៍នៅវត្តអង្គព្រៃទប់ថា ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលចុះមកចែកប្រអប់អនុស្សាវរីយ៍ និងយកចិត្តទុកដាក់លើការថែទាំសុខភាពសម្រាប់មនុស្សចាស់នៅក្នុងឃុំរបស់ខ្ញុំ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ជាចុងក្រោយ ខ្ញុំសំណូមពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យបន្តការងារសុខភាពជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរ ដែលមានវ័យចាស់ជរា និងមានជីវភាពខ្វះខាតតទៅមុខទៀត។ ជាពិសេសបន្តការងារស្រាវជ្រាវ និងផ្សព្វផ្សាយអំពីរបបខ្មែរក្រហមដល់អ្នកជំនាន់ក្រោយឲ្យទូលំទូលាយនៅថ្ងៃអនាគត។

**លោក ជា ណាត** អាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅឃុំមានជ័យ ស្រុកឈូក ខេត្តកំពត បង្ហាញអំពីចំណាប់អារម្មណ៍នៅក្នុងកម្មវិធីចែកប្រអប់អនុស្សាវរីយ៍នៅវត្តអង្គស្វាយឃុំមានជ័យថា ខ្ញុំត្រេកអរដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះមកសួរសុខទុក្ខពន្យល់អំពីរបៀបថែទាំសុខភាព និងចែកប្រអប់អនុស្សាវរីយ៍ដល់ខ្ញុំ និងប្រជាជននៅតាមភូមិដទៃៗ ខ្ញុំមានអារម្មណ៍ធូរ



*អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពត ចូលរួមកម្មវិធីសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ស្បើយក្នុងចិត្ត បន្ទាប់ពីចែករំលែកនូវបទពិសោធន៍ឆ្លងកាត់សម័យសង្គ្រាម និងរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តកម្ពុជា ដែលជាយុវជនជំនាន់ក្រោយបានសិក្សាឈ្វេងយល់ដើម្បីបញ្ចៀសមិនឲ្យកើតមានការសម្លាប់រង្គាលតទៅទៀត។

**លោក ចាប នន** អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិគក ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពត គឺជាអាចារ្យវត្តឈើទាល មានប្រសាសន៍រៀបរាប់អំពីបទពិសោធន៍ជីវិតឆ្លងកាត់សង្គ្រាម និងរបបខ្មែរក្រហមក្នុងកម្មវិធីចែកប្រអប់អនុស្សាវរីយ៍ថា ក្នុងឆ្នាំ១៩៧២ ខ្មែរក្រហមចាប់បញ្ជូនខ្ញុំនិងប្រជាជនដែលមានកម្លាំងរឹងមាំឲ្យទៅធ្វើជាកងទ័ពនៅខេត្តកំពង់ស្ពឺ។ ក្រោយមក ខ្ញុំបានវិលត្រឡប់មកផ្ទះវិញរហូតដល់ឆ្នាំ១៩៧៣ ខ្មែរក្រហមបានប្រមូលផ្តុំប្រជាជន និងចាត់ឲ្យខ្ញុំធ្វើជាឈ្លបឃុំ អស់រយៈពេលប្រហែលជាងមួយឆ្នាំ ក៏បញ្ជូនខ្ញុំ ទៅធ្វើទ័ពស្រុកដើម្បីប្រយុទ្ធជាមួយនឹងទាហាន លន់ នល់ នៅខេត្តតាកែវ រហូតដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃជ័យជម្នះទាំងស្រុងរបស់ខ្មែរក្រហមលើរបប លន់ នល់។ បន្ទាប់ពីច្បាំងឈ្នះ ខ្ញុំឆ្លៀតមកជួបជាមួយឪពុកម្តាយ ប៉ុន្តែខ្មែរក្រហមបែរជាចោទខ្ញុំថាធ្វើខុសវិន័យ និងដាក់ទោសខ្ញុំឲ្យវែកដីម្នាក់ឯងអស់រយៈពេល៣ខែ។ ក្រោយមក ខ្មែរក្រហមរំសាយខ្ញុំពីកងទ័ពមកធ្វើជាយុវជនប្រមូលផ្តុំវិញ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានរៀបការឲ្យខ្ញុំ ជាមួយមិត្តនារី វ៉ាន់ សុន។ នៅក្នុងខែតុលា ឆ្នាំ១៩៧៨ ខ្មែរក្រហមចាត់ខ្ញុំឲ្យមកធ្វើការតាមភូមិវិញ។ ក្រោយមក ខ្មែរក្រហមបានឃុំខ្លួនខ្ញុំក្នុងសាលាឃុំម្រោម និងធ្វើទារុណកម្មខ្ញុំម្តងទៀតដោយសារខ្ញុំបានដកដំឡូងដែលខ្ញុំដាំយកមកហូប។ រហូតមកដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមវាយចូលមក ទើបខ្មែរក្រហមជម្លៀសប្រជាជនចេញភូមិ។ រីឯខ្ញុំដែលជាប់ឃុំឃាំង ត្រូវបានខ្មែរក្រហមដោះលែងឲ្យមករកក្រុមគ្រួសារវិញ។

លោក ចាប នន បន្ថែមទៀតថា ខ្ញុំពិតជារំភើប



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពត ចូលរួមកម្មវិធីសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







និងសប្បាយចិត្តដែលមានអង្គការយកចិត្តទុកដាក់ទៅលើសុខភាពរបស់អ្នកដែលរួចរស់ពីរបបខ្មែរក្រហម។ ក្រោយពីខ្ញុំបានស្តាប់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើបទបង្ហាញ អំពីសុខភាពទាក់ទងជំងឺលើសឈាម ជំងឺទឹកនោមផ្អែម និងជំងឺក្រពះពោះវៀនដែលខ្ញុំកំពុងកើតបានធ្វើឲ្យខ្ញុំមានការយល់ដឹងច្រើនជាងមុនអំពីការថែរក្សាសុខភាពសម្រាប់មនុស្សចាស់។



# វង វិន ៖ ខ្មែរក្រហមឃោសនាថា «ខ្មែរជួយខ្មែរ»

*រឹម ស្រីស្រស់*



វង វិន អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ វង វិន អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃតាម៉ៅ ឃុំគិរីចុងកោះ ស្រុកគិរីវង់ ខេត្តតាកែវ។ ខ្ញុំមានស្រុកកំណើតនៅយ៉ាងយ៉ាវ ខេត្តមាត់ជ្រូក កម្ពុជាក្រោម (បច្ចុប្បន្នប្រទេសវៀតណាម)។ ខ្ញុំមានបងប្អូនប្រាំមួយនាក់ប៉ុន្តែបានស្លាប់កាលពីជំនាន់ធីវគីម្នាក់ និងស្លាប់នៅពេលបច្ចុប្បន្នពីរនាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ម៉ៅ សន (ស្លាប់) និងមានកូនប្រាំមួយនាក់ ស្រីបួននាក់ ប្រុសពីរនាក់។ កាលពីក្មេង ខ្ញុំបានចូលរៀននៅសាលាវត្ត ចំណែកសាលាបាព្រាបគឺជាទីកន្លែងដែលខ្ញុំបានរៀនអក្សរវៀតណាម។

បន្ទាប់មក ខ្ញុំបានបួសចំនួនបួនវស្សានៅក្នុងវត្តទឹកល្អក់ចាប់ពីអាយុ១៦ឆ្នាំរហូតដល់អាយុ២០ឆ្នាំ។ ខ្ញុំចេះភាសាខ្មែរដោយសារតែការបួសរៀននេះ។ បន្ទាប់ពីសឹក ខ្ញុំបានរៀបការនៅយ៉ាងយ៉ាវ (កម្ពុជាក្រោម)។ នៅខែមេសា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានចូលទៅកៀរខ្ញុំមកកម្ពុជាវិញដោយបានឃោសនាថា ឡើងមកកម្ពុជាមកព្រោះ «ខ្មែរជួយខ្មែរ»។ ពេលមកដល់កម្ពុជាដំបូង ខ្ញុំបានឃើញសុទ្ធតែខ្មែរក្រហម។ ចម្ងាយពីព្រំដែនកម្ពុជាទៅដល់ភូមិខ្ញុំរស់នៅប្រហែល ៣០គីឡូម៉ែត្រ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងរយៈពេលមួយថ្ងៃមួយយប់ទើបមកដល់ច្រកសាក្រាំ ស្រុកគិរីវង់ ខេត្តតាកែវ និងបានរស់នៅទីនោះរយៈពេលបីខែ។ ខ្មែរក្រហមបានចែកអង្ករឲ្យខ្ញុំនិងសមាជិកគ្រួសារក្នុងម្នាក់មួយកំប៉ុង។ មួយរយៈក្រោយមក ខ្មែរក្រហមបានឲ្យខ្ញុំ និងប្រជាជនឯទៀតដកស្ទូង និងធ្វើស្រែ។ ខ្ញុំនិងគ្រួសារត្រូវបានកម្មាភិបាលខ្មែរក្រហមផ្លាស់ ពីភូមិមួយទៅភូមិមួយ ដោយខ្ញុំសង្កេតឃើញភូមិទាំងនោះគ្មានមនុស្សរស់នៅឡើយ។

ក្រោយមក ខ្មែរក្រហមបានផ្លាស់ខ្ញុំឲ្យមករស់នៅភូមិអូរកាសា រយៈពេលបីខែ។ នៅកន្លែងនោះ ខ្មែរក្រហមប្រើខ្ញុំឲ្យស្ទូងក្នុងដីមួយហិកតា ប្រើមនុស្សតែ៧ នាក់ប៉ុណ្ណោះឲ្យហើយរួចរាល់ក្នុងមួយថ្ងៃ។ តា ហ៊ុន គឺជាប្រធានភូមិដែលខ្ញុំរស់នៅ។ កម្មាភិបាលខ្មែរក្រហមបានយកឈ្មោះយ៉ាំង, ឈ្មោះលេន, ឈ្មោះនាក់ និងប្រជាជនផ្សេងទៀតទៅវាយចោលដោយប្រាប់ថា «យកទៅរៀនសូត្រ»។ ខ្មែរក្រហមបានយកប្រជាជនទៅវាយចោលដោយសារធ្វើការមិនហើយតាមផែន

ការ, លួច, ខុសសីលធម៌ និងអ្នកដែលសម្បុរសៗ ដែលខ្មែរក្រហមចោទថា ជាជនជាតិវៀតណាមៗ ចំណែកកូនរបស់ខ្ញុំត្រូវបានយាយៗមើលថែទាំៗ កងឈ្លបខ្មែរក្រហមពីរបីនាក់បានមកលបស្តាប់ពេលខ្ញុំនិងគ្រួសាររៀបចំបូលដេក ដូច្នេះខ្ញុំមិនហ៊ាននិយាយគ្នាឡើយៗ ក្រោយមក កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមវាយចូលមក ដូច្នេះខ្មែរក្រហមបានកៀរខ្ញុំ និងគ្រួសារទៅតានី, ត្រាំតាសរ, វត្តត្រពាំងត្រកៀត និងភ្នំដីររមៀលៗ បន្ទាប់មក ខ្ញុំនិងគ្រួសារបានរត់ភៀសខ្លួនរហូតទៅដល់ភ្នំស្រមោចព្រោះខ្មែរក្រហមប្រាប់ថា «ភៀសខ្លួនចេញមួយរយៈសិន» ដោយមានកងឈ្លបខ្មែរក្រហមនាំផ្លូវទៅគ្រប់ទីកន្លែងៗ បន្ទាប់មក ខ្ញុំធ្វើដំណើរពីភ្នំស្រមោចត្រឡប់មកតានី ដោយដើរកាត់តាមវត្តអង្គកែវ វាលទទោក ជាកន្លែងដែលទ័ពវៀតណាមចាំឆែកប្រជាជនដែលពាក់ស្បែកជើងកង់ឡាន ពាក់នាឡិកា និងរបស់របរផ្សេងៗៗ ប្រជាជនទាំងនោះត្រូវបានឃាត់ និងបញ្ជូនទៅដាក់នៅមាត់ជ្រូកៗ បងរបស់ខ្ញុំម្នាក់ត្រូវបានឃាត់ខ្លួនដោយសារគាត់មានកញ្ចក់មូលតូចមួយ ហើយក៏ស្លាប់នៅមាត់ជ្រូកៗ ចំណែកខ្ញុំត្រឡប់មករស់នៅភូមិព្រៃតាម៉ៅដោយប្រកបរបរដុតធ្យូងលក់ៗ




អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ជូនប្រអប់អនុស្សាវរីយ៍ដល់ វង វិនៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គង់ តឹង ៖ ខ្ញុំកើតកូននៅតាមផ្លូវ តែសំណាងល្អបានយាយម៉ីបង្កើយ

**ទី ស៊ីថា**




គង់ តឹង អាយុ៨៦ឆ្នាំ សព្វរស់នៅភូមិល្ងាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និង ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គង់ តឹង អាយុ៨៦ឆ្នាំ មានស្រុកកំណើតនៅល្ងាលើ ឃុំទន្លូងស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិល្ងាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ កាលពីតូចខ្ញុំរស់នៅក្នុងចម្ការកៅស៊ូមួយដែលអ្នកភូមិហៅថា ចម្ការកៅស៊ូភូមិថ្លុក ស្ថិតនៅក្នុងឃុំទន្លូង ដោយមានគ្រួសារជាច្រើនរស់នៅទីនោះ។ ខ្ញុំរស់នៅចម្ការកៅស៊ូភូមិថ្លុកបានមួយរយៈក៏ប្តូរមករស់នៅក្នុងភូមិល្ងាវិញ។ ខណៈនោះមានជនជាតិបារាំងបានចូលមកភូមិរបស់ខ្ញុំ និងបានវាស់ដីដាំកៅស៊ូ ហើយខ្ញុំដែលមានអាយុប្រហែល១២-១៣ឆ្នាំ ក៏បានទៅបោសស្លឹកកៅស៊ូឲ្យបារាំងក្នុងមួយថ្ងៃទទួលបានប្រាក់៥-៦រៀល។

ខ្ញុំបានរៀបការនៅអាយុ១៦ឆ្នាំ ជាមួយប្តីឈ្មោះ ឈឹង។ ខ្ញុំមានកូន៩នាក់ ស្លាប់៤នាក់ នៅរស់៥នាក់ គឺប្រុស៣នាក់ និងស្រី២នាក់។ កូនប្រុសច្បងរបស់ខ្ញុំស្លាប់ម្នាក់ នៅពេលខ្មែរក្រហមជ្រើសរើសកូនរបស់ខ្ញុំឲ្យចូលធ្វើយោធា ហើយមានការទម្លាក់គ្រាប់បែកត្រូវចំរណ្តៅដែលកូនរបស់ខ្ញុំចូលទៅលាក់ខ្លួនស្ថិតនៅខាងស្រែតានង។ នៅសម័យសង្គ្រាមវៀតណាម ប្រជាជននៅក្នុងភូមិបានរត់ចេញទៅនៅក្នុងព្រៃ និងជីករណ្តៅត្រង់សេទុកលាក់ខ្លួន។ ខ្ញុំឃើញរថក្រោះអាមេរិកាំងបើកឆ្លងកាត់ភូមិ ប៉ុន្តែមិនបានធ្វើបាប

ប្រជាជនទេ។ បន្ទាប់មក មានកងទ័ពវៀតកុងចូលមកតាមក្រោយៗ នៅអំឡុងពេលនោះ ក៏មានការទម្លាក់គ្រាប់បែកធ្វើឲ្យ តាកុយ និងយាយក្អែក ស្លាប់ ពេលចេញទៅផ្ចូតទឹកនៅតាមអូរ។ ចំណែកនៅភូមិបេងកោងក៏មានប្រជាជនស្លាប់ដែរ នៅពេលដែលអ្នកទាំងនោះចេញទៅជម្រះស្មៅនៅចម្ការ ហើយគ្រាប់បែកធ្លាក់មកចំៗ ខ្ញុំស្គាល់មេបញ្ជាការរបស់កងទ័ពវៀតកុងឈ្មោះ តាទៀន និង តាតាន។ អាមេរិក និងវៀតកុងបានចូលមកភូមិរយៈពេលប្រហែល២ឆ្នាំ ក៏ដកទ័ពចេញទៅវិញអស់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចំនួន៣-៤គ្រួសារពីភ្នំពេញឲ្យមកនៅភូមិរបស់ខ្ញុំប៉ុន្តែក្រោយមកមិនដឹងខ្មែរក្រហមយកប្រជាជនជម្លៀសទាំងនោះទៅទីណាឡើយ។ ចំណែកខ្ញុំនៅធ្វើស្រែចម្ការធម្មតា ហើយមួយរយៈក្រោយប្រជាជននៅក្នុងភូមិចាប់ផ្តើមធ្វើការផ្ការប្រវាស់ដៃ និងចូលជាសហករណ៍ ប៉ុន្តែមិនទាន់ប្រមូលទ្រព្យសម្បត្តិយកទៅដាក់រួមទេ។ មិនយូរប៉ុន្មានខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិល្ងាលើឲ្យទៅរស់នៅភូមិចង្កី ហើយនៅទីនោះខ្មែរក្រហមប្រាប់ខ្ញុំឲ្យប្រមូលទ្រព្យសម្បត្តិដាក់រួម។ ខ្ញុំរស់នៅភូមិចង្កីបានមួយរយៈ ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅរស់នៅស្រុកឆ្លូង ខេត្តក្រចេះ។ នៅទីនោះខ្ញុំទទួលដំណឹងថាកូនប្រុសរបស់ខ្ញុំម្នាក់ទៀតបានស្លាប់។ ប្តីរបស់ខ្ញុំតូចចិត្តស្តាយស្រណោះកូនៗ ប្តីរបស់ខ្ញុំហូបបាយមិនចូល គិតតែយំនឹកកូន ព្រោះកាលពេលគាត់រស់នៅភូមិចង្កី កូនប្រុសខ្ញុំធ្លាប់ទៅលេងគាត់ម្តង រួចនិយាយថា «ពេលខ្ញុំមកលេងឪលើកក្រោយ ចាំខ្ញុំយកអាវមកឲ្យឪមួយ» ប៉ុន្តែមិនទាន់បានមកលេងផង ក៏ត្រូវខ្មែរក្រហមសម្លាប់។ កូនរបស់ខ្ញុំដែលធ្វើកងទ័ពខ្មែរក្រហមនោះក៏ធ្លាប់មកលេងខ្ញុំនៅឆ្លូងដែរ ហើយខ្ញុំហៅកូនឲ្យហូបពោត ប៉ុន្តែកូនរបស់ខ្ញុំបានឆ្លើយថាមិនហូបទេ។ លុះដល់ពេលយប់ខ្មែរក្រហមចាប់កូនរបស់ខ្ញុំនិងមិត្តភក្តិកូនរបស់ខ្ញុំម្នាក់ទៀតយកទៅសម្លាប់ចោលនៅមាត់ព្រែក ប៉ុន្តែមិត្តភក្តិកូនរបស់ខ្ញុំបានរត់រួចខ្លួន ស្លាប់តែកូនរបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំរស់នៅស្រុកឆ្លូងមិនបានប៉ុន្មានផងក៏ផ្លាស់ទៅរស់នៅម្ចិចវិញ។ នៅទីនោះខ្ញុំដើរបេះបន្លែ ស្លឹកឈើ ដែលខ្ញុំអាចបេះបានយកមកហូប ព្រោះមិនមានអាហារ ហើយកាលនោះខ្ញុំពោះធំ៣ខែ។

ប្តីរបស់ខ្ញុំបានស្លាប់នៅឆ្លូង ដោយសារតែមានអ្នកភូមិឈ្មោះ ប៉ាន់បានមកបបួលគាត់រត់ត្រឡប់ទៅស្រុកកំណើតវិញ ហើយត្រូវខ្មែរក្រហមចាប់ពួកគាត់បាននៅឆ្លូង និងយកទៅសម្លាប់ចោល ទាំងពីរនាក់។ ក្មួយរបស់ប្តីខ្ញុំដែលរត់ទៅតាមក្រោយ ប៉ាន់ និងប្តីរបស់ខ្ញុំដែលបានដឹងរឿងនោះបានមកប្រាប់ខ្ញុំថា ពូបានស្លាប់ហើយ។ ខ្ញុំត្រូវបានអ្នកភូមិម្ចិចឃាត់មិនឲ្យត្រឡប់មកស្រុកកំណើតវិញ ព្រោះខ្លាចខ្មែរក្រហមចាប់យកទៅសម្លាប់ទៀត។ នៅទីនោះ ប្រជាជនដែលមានសណ្តានចិត្តល្អបានលួចដាំបាយឲ្យខ្ញុំហូបឆ្អែតបានពីរពេល។ ក្រោយមកខ្ញុំចេញដំណើរពីភូមិម្ចិចដល់ភូមិកំពង់រទេះ ស្រាប់តែឃើញកងទ័ពរំដោះ និងកងទ័ពវៀតណាមចូលមកដល់។ ខណៈនោះ ស្រាប់តែខ្ញុំឈឺពោះកើតកូននៅតាមផ្លូវ ហើយសំណាងល្អមានឆ្មបម្នាក់បានជួយបង្កើតកូនឲ្យខ្ញុំ។ ខ្ញុំបានស្នាក់អាស្រ័យនៅផ្ទះយាយម៉បនោះមួយយប់។ ដោយសារតែកូនរបស់ខ្ញុំកើតមកតូចពេក ទើបអ្នកស្រុកបានបង្ហាប់កូនរបស់ខ្ញុំថា «អាដបទឹកសុទ្ធ» ហើយបាននិយាយប្រាប់កូនស្រីរបស់ខ្ញុំម្នាក់ទៀតដែលកំពុងពរប្អូនដែលទើបនឹងកើតថា «បីវាធ្វើអ្វី! មិនបោះវាចោលទៅ!»

ពេលនោះកូនស្រីរបស់ខ្ញុំតបទៅអ្នកស្រុកវិញថា ខ្ញុំមិនបោះបង់ប្អូនរបស់ខ្ញុំទេ។ លុះព្រឹកឡើងទើបមាន ឡានកងទ័ពវៀតណាមមកដឹកខ្ញុំត្រឡប់ទៅស្រុកកំណើតវិញ។ ខ្ញុំនិងកូនចុះពីឡានរួចទៅស្នាក់នៅភូមិក្តួលរយៈពេល៣យប់ ទើបចេញទៅរស់នៅភូមិពងទឹកបណ្តោះអាសន្នរយៈពេលជិតមួយខែទៀត។ នៅពេលនោះ អ្នកភូមិមកប្រាប់ខ្ញុំថា ប្រសិនបើមានកន្លែងណារស់នៅ ចេញទៅរស់នៅកន្លែងនោះទៅ ដូច្នេះខ្ញុំក៏សម្រេចចិត្តមករស់នៅស្រុកកំណើតនៅភូមិល្ងាលើវិញ។

# គិន ម៉ន ៖ ខ្ញុំចូលកងចល័តតាមការឃោសនារបស់ប្រធានសហករណ៍

## ថុន ស្រីពេជ្រ



គិន ម៉ន អាយុ៧៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិបុស្សឫស្សីជ្រាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គិន ម៉ន អាយុ៧៨ឆ្នាំ កើតនៅភូមិត្រោក ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ កាលនៅវ័យកុមារ ខ្ញុំបានចូលរៀននៅសាលាវត្តសង្កែជ្រុំ។ នៅឆ្នាំ១៩៦៤ ខ្ញុំបានឈប់រៀនដោយសារជីវភាពក្រីក្រ។ នៅអាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៦៧ ខ្ញុំបានបួសជាសង្ឃនៅវត្តសង្កែជ្រុំ។ នៅឆ្នាំ១៩៦៩ ឪពុកម្ដាយរបស់ខ្ញុំបានចូលស្ដីដណ្ដឹងកូនក្រមុំរបស់អ្នកភូមិឈ្មោះ ចន់ អយ ឲ្យខ្ញុំ។ បន្ទាប់មកយើងបានរៀបការជាប្ដីប្រពន្ធ។

ក្រោយរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ ខ្ញុំ និងប្រពន្ធបានភៀសខ្លួនទៅរស់នៅខាងជើងស្រុកមេសាង ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែកៗ រហូតដល់យោធាខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបែងចែកឲ្យប្រជាជនធ្វើការងាររួមគ្នា។ ដំបូង ប្រធានកងប្រើខ្ញុំឲ្យភ្ជួរស្រែនៅក្នុងភូមិ។ បន្ទាប់ពីភ្ជួរស្រែរួចរាល់ហើយ ប្រធានកងប្រើខ្ញុំឲ្យចេញទៅរែកកណ្ដាប់វិញ។

រហូតដល់ឆ្នាំ១៩៧៧ ប្រធានកងបញ្ចូលខ្ញុំក្នុងកងចល័ត និងបានចាត់តាំងខ្ញុំឲ្យទៅជីកអាងស្តុកទឹកនៅឃុំព្រៃឃ្នេសរយៈពេលពីរខែ។ តមកប្រធានកងបញ្ជូនខ្ញុំទៅស្ថានីយ៍ខ្សាច់សដើម្បីលើកទំនប់។ នៅទីនោះ ខ្ញុំបានហូបឆ្អែតជាងពេលដែលខ្ញុំធ្វើការនៅក្នុងភូមិ។ នៅស្ថានីយ៍ខ្សាច់ស មានត្រកួន ផ្កាកំប្លោកព្រលិតរំចង់ និងស្លឹកឈើព្រៃផ្សេងៗទៀត។ ថ្ងៃខ្លះខ្ញុំហូបសម្លម្ជូរ និងថ្ងៃខ្លះខ្ញុំហូបសម្លកកូរត្នោត។ ទោះបីយ៉ាងណាខ្ញុំមិនមានផ្ទះស្នាក់នៅសមរម្យទេ គឺរាល់យប់ខ្ញុំដេកនៅតាមវាលជិតកន្លែងធ្វើការ។

ខ្ញុំធ្វើការនៅស្ថានីយ៍ខ្សាច់សបានរយៈពេលមួយខែ ប្រធានកងក៏បញ្ជូនខ្ញុំត្រឡប់មកភូមិវិញ ដើម្បីដឹកនាំសមាជិកកងចំនួន៣០នាក់ ដើរប្រមូលអាចម៍គោយកមកលាយធ្វើជីកំប៉ុស។ ព្រឹកឡើង ខ្ញុំចាត់តាំងឲ្យសមាជិកក្នុងកងរបស់ខ្ញុំកាន់ល្អីម្នាក់មួយ រួចហើយឲ្យចេញទៅរើសអាចម៍គោ។ លុះពេលល្ងាចឡើងក្រោយពីចប់ម៉ោងការងារ ខ្ញុំត្រូវរាយការណ៍ទៅកាន់ថ្នាក់លើអំពីសកម្មភាពការងារនៅក្នុងក្រុមរបស់ខ្ញុំ។ ខ្ញុំមិនដែលលើករឿងមិនល្អរបស់ក្រុមខ្ញុំ ឲ្យអង្គការដឹងឡើយ បើទោះបីជាខ្ញុំដឹងថាសមាជិកក្រុមរបស់ខ្ញុំធ្វើការមិនយកចិត្តទុកដាក់ និងខ្ជិលក៏ដោយ។

នៅចុងឆ្នាំ១៩៧៨ កួយ គឺជាប្រធានសហករណ៍

បានឃោសនាកុហក់ខ្ញុំថា នឹងបញ្ជូនខ្ញុំឲ្យទៅធ្វើជាកម្មករនៅរោងម៉ាស៊ីនស្រូវ ប៉ុន្តែតាមពិតបញ្ជូនខ្ញុំទៅធ្វើកងទ័ពដើម្បីត្រៀមប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមៗ ពេលនោះខ្ញុំមិនចង់បែកពីប្រពន្ធ និងកូនឡើយ។ មុនពេលដែលខ្ញុំរៀបចេញដំណើរទៅធ្វើទ័ព ប្រពន្ធរបស់ខ្ញុំបានវេចដំឡូងឲ្យខ្ញុំទុកហូបតាមផ្លូវ។ ប៉ុន្តែខ្ញុំបានធ្វើឲ្យជ្រុះដំឡូងអស់ព្រោះក្នុងចិត្តរបស់ខ្ញុំនៅតែគិតអាល័យប្រពន្ធនិងកូនៗ ខ្ញុំស្ដាយយ៉ាងខ្លាំងចំពោះដំឡូងដែលប្រពន្ធខ្ញុំវេចខ្ចប់ឲ្យ។ នៅវេលាប្រហែលម៉ោង៥ល្ងាច យោធាខ្មែរក្រហមម្នាក់មកហៅខ្ញុំចេញដំណើរទៅ។ នៅវេលាម៉ោង៦ល្ងាច ខ្ញុំបានទៅដល់ឃុំព្រៃឃ្នេស ដែលពេលនោះយោធាខ្មែរក្រហមប្រមូលមនុស្សដែលត្រូវចូលធ្វើកងទ័ពបានចំនួន១គ ស្មើនឹង១៥០នាក់ ទៅជាមួយដែរ។

ខ្ញុំដើរបន្តទៅវត្តស្វាវ ស្ថិតនៅឃុំប្រេស ស្រុកមេសាង ហើយនៅតាមផ្លូវមានមនុស្សមករួមដំណើរជាបន្តបន្ទាប់បន្ថែមទៀត សរុបប្រមាណ៨០០នាក់មកពីឃុំទាំង៨ ក្នុងស្រុកមេសាង។ ខ្ញុំនិងអ្នកឯទៀតសម្រាកនៅវត្តស្វាវមួយយប់។ លុះវេលាម៉ោង៣រសៀល នៅថ្ងៃបន្ទាប់ ខ្ញុំនិងអ្នកឯទៀតបានឡើងជិះឡានបន្តដំណើរទៅមុខទៀត។ អ្នកបើកឡានបានជូនខ្ញុំនិងអ្នកឯទៀតទៅដល់ត្រពាំងផ្លុង រួចហើយឲ្យយើងធ្វើដំណើរដោយថ្មើរជើងបន្ត។ ខ្ញុំបានដើរកាត់ទឹកកាត់ព្រៃ និងជាន់បន្លាមុតសុះជើង។ ខ្ញុំដើររហូតដល់ចម្ការអំពៅ ក៏ឃើញកងទ័ព សមមិត្តរិន ដើរចេញពីក្នុងព្រៃកាត់មុខក្រុមរបស់ខ្ញុំ។ ខ្ញុំនិងក្រុមបានឈប់សម្រាកនៅចម្ការអំពៅមួយរយៈខ្លី រង់ចាំឲ្យកងទ័ពសមមិត្តរិន ដើរទៅផុត ទើបក្រុមរបស់ខ្ញុំដើរចេញពីចម្ការអំពៅមក។ ខ្ញុំដើរបានចម្ងាយពីរគីឡូម៉ែត្រ ក៏ឃើញខិតប័ណ្ណរបស់កងទ័ពសមមិត្តរិនជ្រុះនៅលើដី។ ខ្ញុំបានរើសខិតប័ណ្ណនោះមកអានដែលនៅលើខិតប័ណ្ណនោះសរសេរថា «មិត្តឯងចង់ចូលយួន! ងាប់!» ឃើញដូច្នេះ ខ្ញុំក៏ហែកខិតប័ណ្ណនោះចោល រួចបន្តដំណើរទៅមុខរហូតដល់ខ្សាច់ខោល ស្ថិតនៅជាប់ព្រំដែនវៀតណាម។

ទៅដល់ទីនោះ មានហេតុការណ៍មួយដែលខ្ញុំភ្ញាក់ផ្អើល និងរន្ធត់ គឺកងទ័ពខ្មែរគ្នាឯងបានបាញ់សម្លាប់គ្នាឯង។ ដោយសារមានបាញ់ប្រហារគ្នាខ្លាំង ខ្ញុំចាប់ផ្ដើមជីកត្រង់សេ (លេណដ្ឋាន) ដើម្បីត្រៀមចូលប្រយុទ្ធ។ ដោយសារតំបន់នោះដីឆាប់ជ្រាបទឹក ដូច្នេះទឹកបានជ្រាបចេញមកពេញត្រង់សេធ្វើឲ្យខ្ញុំពិបាកដកដង្ហើមយ៉ាងខ្លាំង។ ខ្ញុំបានអើតក្បាលឡើងលើដើម្បីដកដង្ហើម និងត្រៀមប្រយុទ្ធជានិច្ច។ ខ្ញុំត្រាំនៅក្នុងទឹកអស់រយៈពេល៣យប់៣ថ្ងៃ ធ្វើឲ្យរាងកាយរបស់ខ្ញុំស្ពឹក និងមិនអាចធ្វើចលនាបាន។ កងទ័ពនៅក្នុងអង្គភាពជាមួយខ្ញុំ បានបញ្ជូនខ្ញុំមកព្យាបាលនៅមន្ទីរពេទ្យស្រុកអូរាំងឪ។ ពេទ្យបានចាក់ថ្នាំឲ្យខ្ញុំ និងឲ្យថ្នាំមកខ្ញុំលេប ប៉ុន្តែនៅតែមិនធូរស្បើយ។ ឃើញដូច្នេះពេទ្យបានបញ្ជូនខ្ញុំបន្តទៅព្យាបាលនៅមន្ទីរពេទ្យមួយទៀតស្ថិតនៅវត្តគងជ័យ។ តាហាន គឺជាគ្រូពេទ្យនៅវត្តគងជ័យបានជួយព្យាបាលខ្ញុំរហូតបានធូរស្រាល ស្រាប់តែកងទ័ពមកពីនិរតីផ្ទោងគ្រាប់ចូលមក ដូច្នេះខ្ញុំរួមជាមួយអ្នកជំងឺផ្សេងទៀត សរុបចំនួន២៥០នាក់បានចាកចេញពីវត្តគងជ័យ ឆ្ពោះទៅកាន់ទន្លេតូច។

នៅពេលខ្ញុំដល់ទន្លេតូច ស្រាប់តែមានបុរសម្នាក់បានប្រាប់ខ្ញុំថា យោធាប៉ុល ពតនៅរង់ចាំខាងមុខគឺនៅរង់ចាំវាយសម្លាប់មនុស្សចោលនៅមាត់ទន្លេ ហើយប្រសិនបើខ្ញុំទៅមុខទៀតនឹងត្រូវស្លាប់មិនខាន។ ខ្ញុំនឹកគិតនៅក្នុងចិត្តថា ខ្ញុំមិនគួរស្លាប់នៅក្នុងទឹកទេ ទើបខ្ញុំបបួល តាហាន ត្រឡប់មកវិញដោយបាននាំអ្នកជំងឺផ្សេងទៀតមកជាមួយគ្នាដែរ។ ក្រុមរបស់ខ្ញុំបានធ្វើដំណើរមកដល់ស្វាយសុខោ ក៏ឃើញមនុស្សស្លៀកពាក់ពណ៌ខ្មៅជាច្រើនពីចម្ងាយ។ ខ្ញុំគិតថានឹងមានសភាពការណ៍មិនស្រួលហើយ ទើបខ្ញុំចាប់ផ្ដើមចាត់វិធានការបំបែកក្រុម ដោយក្នុងមួយក្រុមមានមនុស្សចំនួនប្រាំទៅប្រាំមួយនាក់ ដើម្បីកុំឲ្យអ្នកផ្សេងចាប់អារម្មណ៍។ ខ្ញុំធ្វើដំណើរផុតស្វាយអន្ទរបន្តិច ក៏បត់ទៅផ្ទះវិញ។ ដំបូងខ្ញុំមិនទាន់ហ៊ានចូលក្នុងភូមិទេ ព្រោះខ្លាចមេភូមិរករឿង និងចាប់ខ្លួន។ ខ្ញុំស្នាក់នៅផ្ទះបងប្រុសរបស់ខ្ញុំស្ថិតនៅភូមិគ្រោក រហូតដល់របបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំមករស់នៅភូមិបុស្សស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែងរហូតមកដល់សព្វថ្ងៃ។

# ជា សុខន ៖ សុខចិត្តធ្វើជាមនុស្សឆ្កួត ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល

សៀង កញ្ញា




ជា សុខន ហៅ ខុយ បច្ចុប្បន្នរស់នៅក្នុងភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជា សុខន ហៅ ខុយ បច្ចុប្បន្នរស់នៅក្នុងភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានតួនាទីជា ទីប្រឹក្សាឃុំលាយបូរតាំងពីឆ្នាំ២០១៧មក។ ខ្ញុំមានប្រពន្ធឈ្មោះ ស សែន កើតនៅឆ្នាំ១៩៥០។ ខ្ញុំមានកូនចំនួន៥នាក់ ក្នុងនោះមានកូនប្រុសចំនួន៣នាក់។ ខ្ញុំមានឪពុកឈ្មោះ ជា ខឹម ស្លាប់តាំងពីខ្ញុំអាយុ២ឆ្នាំ នៅរបបសង្គមរាស្ត្រនិយម។ ចំណែកម្តាយរបស់ខ្ញុំឈ្មោះ ស នឹម ស្លាប់នៅឆ្នាំ១៩៨៥ ដោយសារជំងឺចាស់ជរា។

ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ ក្នុងនោះមានស្រី២នាក់ ហើយខ្ញុំគឺជាកូនទី២ក្នុងគ្រួសារ។ ខ្ញុំកើតនៅឆ្នាំ១៩៤៦ នៅភូមិត្រពាំងគ្រាច ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ កាលពីជំនាន់សង្គមរាស្ត្រនិយម ពេលដែលសម្តេចព្រះ នរោត្តម សីហនុ ប្រកាសឯករាជ្យ ទ្រង់បានយកចិត្តទុកដាក់ទៅលើវិស័យអប់រំ កសិកម្ម និងវប្បធម៌ខ្លាំងណាស់។ បន្ទាប់ពីឪពុកខ្ញុំស្លាប់ ម្តាយខ្ញុំក៏យកប្តីថ្មីឈ្មោះ ខៀវ គង់។ ឪពុកថ្មីរបស់ខ្ញុំតែងតែលើកទឹកចិត្តឲ្យខ្ញុំរៀន ដោយគាត់បាននិយាយថា «សុខចិត្តលក់ដីឲ្យកូនរៀន ប្រសើរជាងទុកដីឲ្យកូនធ្វើស្រែ»។ បន្ទាប់ពីទទួលបានការទំនុកបម្រុងពីគ្រួសារហើយ ខ្ញុំខិតខំប្រឹងប្រែរៀនសូត្រទាំងភាសាបារាំង ភាសាអង់គ្លេស និងភាសាខ្មែរ។

កាលនោះ ខ្ញុំរៀនភាសាបារាំងតាំងពីថ្នាក់មូលដ្ឋាន ដោយមានគ្រូ ប៊ុន ឆិន និង គ្រូ ប៊ុន ហេង គឺជាអ្នកបង្រៀន។ ចំណែកមុខវិជ្ជាភាសាខ្មែរ ខ្ញុំរៀនជាមួយលោកគ្រូ ត្រឹង ផា គឺជាអាចារ្យបិដក។ គ្រូកាលពីជំនាន់នោះមិនហ៊ានវាយសិស្សទេ ប៉ុន្តែគ្រូដាក់វិន័យតឹងរ៉ឹងណាស់ចំពោះសិស្ស។

នៅឆ្នាំ១៩៦៩ ខ្ញុំរៀនដល់ថ្នាក់ទី១ ដែលបច្ចុប្បន្នស្មើនឹងថ្នាក់ទី១២ ប៉ុន្តែខ្ញុំមិនទាន់បានប្រឡងទេ ក៏មានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ នៅពេលនោះ ខ្ញុំក៏សម្រេចចិត្តឈប់រៀន។ បន្ទាប់ពីឈប់រៀន ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់ខ្ញុំសព្វថ្ងៃនៅក្នុងភូមិបឹង ឃុំលាយបូរ។ មួយរយៈក្រោយមក ខ្ញុំប្រឡងជាប់ចូលធ្វើជាប៉ូលិស លន់ នល់ និងមានតួនាទីការពារសន្តិសុខនៅទីក្រុងភ្នំពេញ។ ខ្ញុំបានយកប្រពន្ធមកនៅជាមួយខ្ញុំដែរ។ ចាប់ពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៥ កើតមានចលាចលកាន់តែខ្លាំងនៅក្នុងក្រុងភ្នំពេញ ធ្វើឲ្យការងារខ្ញុំកាន់តែមមាញឹកខ្លាំងដែរ។ នៅអំឡុងពេលនោះប្រពន្ធខ្ញុំមានផ្ទៃពោះ ហើយដោយសារខ្លាចមិនមានសុខវត្ថិភាព ខ្ញុំក៏ជូនប្រពន្ធមកស្រុកកំណើតវិញដើម្បីឲ្យម្តាយក្មេកជួយមើលថែទាំ។ ពេលមកដល់ស្រុកកំណើត ខ្មែរក្រហមឲ្យខ្ញុំដោះសម្លៀកបំពាក់ដែលជាឯកសណ្ឋានប៉ូលិសចេញ ហើយឲ្យខ្ញុំស្លៀកសម្លៀកបំពាក់ធម្មតាវិញ។ កាលនោះ ខ្មែរក្រហមមិនទាន់ធ្វើបាបទាហាន លន់ នល់ ទេ។

នៅពេលដែលយោធាខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរប្រហមបែងចែកប្រជាជនជាបីក្រុម ទីមួយគឺជាក្រុមមូលដ្ឋាន ទីពីគឺជាក្រុមត្រៀម និងទីបីគឺក្រុម១៧មេសា។ ខ្មែរក្រហមប្រកាសដើម្បីប្រមូលអ្នកដែលធ្លាប់ធ្វើជាមន្ត្រីកាលពីសម័យ លន់ នល់ ឲ្យមកជួបជុំគ្នា។ ខ្មែរក្រហមបាននិយាយអួសទាញថា អ្នកណាធ្វើការងារអ្វីកាលពីជំនាន់ លន់ នល់ នឹងឲ្យធ្វើការងារនោះវិញ។ ដោយសារតែខ្វះការគិតពិចារណា ប្រជាជនភាគច្រើនបានទៅបង្ហាញខ្លួន និងប្រាប់ពីតួនាទីរបស់ខ្លួនឲ្យខ្មែរក្រហមដឹង ដោយសង្ឃឹមថានឹងបានការងារធ្វើ និងមានមុខតំណែងដូចដើម។ ក្នុងនោះក៏មានអ្នកមួយចំនួនដែលមានចិត្តលោភលន់ ក៏កុហកខ្មែរក្រហមថាខ្លួនធ្លាប់ធ្វើការងាររដ្ឋ តែតាមពិតទៅជាកសិករធម្មតា។ ដោយសារគិតថានឹងបានដំណែងល្អ ប៉ុន្តែខុសពីការរំពឹងទុក អ្នកទាំងនោះត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់។ ចំណែកខ្ញុំដោយសារតែធ្លាប់សិក្សារៀនសូត្រ និងដឹងពីការឃោសនារបស់ខ្មែរក្រហម ដូច្នេះខ្ញុំមិនបានប្រាប់ខ្មែរក្រហមថា ខ្ញុំធ្លាប់ធ្វើជាប៉ូលិសឡើយ ហើយខ្ញុំធ្វើពុតជាមនុស្ស



ជា សុខន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្កួតៗ ទោះបីខ្ញុំធ្វើឆ្កួតយ៉ាងណាក៏ដោយ ក្រោយមកខ្មែរក្រហមមកសួរនាំខ្ញុំម្តងទៀត ប៉ុន្តែពេលនោះខ្ញុំកុហកថា ខ្ញុំនៅតែស្រែ មិនដែលធ្វើជាមន្ត្រីបុរាជការទេតាំងពីដើមមកៗ ដោយសារតែឃើញខ្ញុំនិយាយដូចជាមនុស្សដែលមានសតិមិនសូវគ្រប់ ខ្មែរក្រហមលែងសួរនាំតទៅទៀតៗ

តាំងពីខ្ញុំនៅរៀន ខ្ញុំតែងតែចងចាំឃ្លាមួយថា «ផ្លូវវៀចកុំបោះបង់ ផ្លូវត្រង់កុំចរយាត្រា ឈានឈរឈប់ឲ្យពិចារណា ឲ្យរំពឹងរំពៃគ្រប់»ៗ ឃ្លានេះមានន័យពេញលេញដែលអាចឲ្យខ្ញុំប្រើ និងអនុវត្តផ្ទាល់បាននៅក្នុងរបបខ្មែរក្រហមៗ ចំណែកខ្មែរក្រហមក៏មានឃ្លារបស់ខ្លួនដែរគឺ «ចាប់មនុស្សច្រឡំ ប្រសើរជាងដោះលែងមនុស្សច្រឡំ» ដែលមានន័យថាបើចាប់អ្នកដែលមិនមានកំហុសច្រឡំ ប្រសើរជាងដោះលែងអ្នកដែលមានកំហុសច្រឡំៗ បន្ទាប់មក ខ្មែរក្រហមបានឲ្យខ្ញុំរែកអាចម៍គោដាក់ស្រែ ទោះបីគិតថាខ្ញុំគឺជាមនុស្សឆ្កួតក៏ដោយ គឺប្រើខ្ញុំមិនឲ្យមានពេលសម្រាកទេៗ បន្ទាប់ពីរែកអាចម៍គោ ខ្មែរក្រហមបានប្រើខ្ញុំឲ្យបបររទេះគោដើម្បីដឹកទឹកទៅឲ្យអ្នកនៅតាមកងៗ

ពេលនោះខ្ញុំឆ្លៀតឱកាសដើម្បីផ្គាប់ចិត្តអ្នកជុំវិញខ្លួនខ្ញុំទាំងអស់ៗ ខ្ញុំដឹកទឹកឲ្យប្រធានកងឲ្យឈ្លប និងឲ្យកម្មាភិបាល ធ្វើឲ្យអ្នកទាំងនោះអាណិតស្រឡាញ់ខ្ញុំៗ ខ្ញុំរស់នៅសុខ និងមិនមានអ្នកធ្វើបាបខ្ញុំឡើយៗ

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះ ពេលនោះខ្ញុំសប្បាយចិត្តណាស់ព្រោះដឹងថាប្រទេសជិតមានសន្តិភាពហើយៗ ខ្ញុំមិនបានរត់ភៀសខ្លួនទៅណាឡើយ ព្រោះដឹងថាកងទ័ពវៀតណាមចូលមកក្នុងគោលបំណងល្អៗ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំត្រឡប់មករស់នៅភូមិបឹងដែលជាស្រុកកំណើតខាងប្រពន្ធរបស់ខ្ញុំៗ មួយរយៈពេលក្រោយមក ខ្ញុំប្រឡងជាប់ជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ហើយតមកក៏ឡើងជានាយកនៅអនុវិទ្យាល័យលាយបូរ និងជានាយករងវិទ្យាល័យលាយបូរៗ ក្រោយពីចូលនិវត្តន៍ពីនាយករងវិទ្យាល័យលាយបូរ នៅឆ្នាំ២០១៧ ខ្ញុំបានចូលធ្វើការក្នុងសាលាឃុំ ដែលមានងារជាទីប្រឹក្សាឃុំរហូតមកដល់បច្ចុប្បន្នៗ




ជា សុខន និងមន្ត្រីនៅសាលាឃុំលាយបូរ ព្រមទាំងអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ថតរូបជុំគ្នាៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជុំ ហាច ៖ បងរបស់ខ្ញុំ ៨ នាក់ ត្រូវខ្មែរក្រហមសម្លាប់

ទូច វណ្ណាត




ជុំ ហាច ទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
( លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា )

ខ្ញុំឈ្មោះ ជុំ ហាច អាយុ៦១ឆ្នាំ រស់នៅភូមិទី១២ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ជុំ សំ និងម្ដាយឈ្មោះ នង កេង និងមានបងប្អូនបង្កើតចំនួន៨ នាក់។ កាលពីក្មេងខ្ញុំរៀននៅសាលាបឋមសិក្សាចុងកោះរហូតដល់ថ្នាក់ទី១១។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០មានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្ដម សីហនុ បន្ទាប់មកក៏មានបាតុកម្មទាមទារអំណាចថ្វាយព្រះអង្គវិញ។ ពេលនោះខ្ញុំរស់នៅជាមួយក្រុមគ្រួសារ។ នៅឆ្នាំ១៩៧២ ខ្ញុំឈប់រៀនដោយសារមានការវាយប្រយុទ្ធគ្នាខ្លាំងរវាងកងទ័ពរំដោះខ្មែរក្រហម និងកងទ័ព លន់ នល់។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសារខ្ញុំរត់ភៀសខ្លួនទៅរស់នៅ ខាងកោះចិនបានរយៈមួយឆ្នាំ ក៏វិលត្រឡប់មករស់នៅស្រុកកំណើតវិញ។

នៅឆ្នាំ១៩៧៥ អង្គការចាត់តាំងខ្ញុំឲ្យធ្វើការងារជាក្រុមនៅក្នុងកងប្រវាស់ដៃ គឺនៅពេលយើងប្រមូលផលដំណាំរួចហើយ ត្រូវចែកផលដំណាំគ្នាហូប។ នៅពេលនោះអង្គការបង្កើតក្រុមសិល្បៈដើម្បីជំរុញដល់ការបង្កបង្កើនផល។ ខ្ញុំក៏បានចូលរួមក្នុងកងសិល្បៈដែរ ហើយត្រូវបានជ្រើសរើសជាតួសម្ដែង។

នៅឆ្នាំ១៩៧៦ អង្គការចាត់តាំងខ្ញុំឲ្យទៅ វែកដីជីកប្រឡាយ លើកទំនប់ ដកស្ទូង និងជញ្ជូនសំណាបនៅ នៅការដ្ឋានឆ្ន័ត្រ។ ខ្ញុំធ្វើការពីម៉ោង៦ដល់ម៉ោង១១ថ្ងៃត្រង់ទើបសម្រាកហូបបបរ និងចាប់ផ្តើមធ្វើការបន្តពីម៉ោង១ដល់ម៉ោង៥ល្ងាច។ ចាប់ពីម៉ោង៦ដល់ម៉ោង៧យប់ អង្គការចាត់ខ្ញុំឲ្យធ្វើការងារសង្គមនិយម ដូចជា កាប់ទន្ទ្រានខែត្រ កំប្លោក យកមកធ្វើជី។

នៅឆ្នាំ១៩៧៧ អង្គការចាត់តាំងខ្ញុំឲ្យជញ្ជូនសំណាបយកឲ្យកងចល័តស្ទូង ដោយពេលនោះខ្ញុំត្រូវអូសសំណាបកាត់តាមប្រឡាយ ទឹកដែលមានប្រវែង ៨គីឡូម៉ែត្រ និងមានឈ្លើងជាច្រើនទាមខ្ញុំ។ ប្រធានកងចល័តខ្ញុំ បានយកបបរចាក់ចូលក្នុងធុងសាំងធំ រួចយកប្រ៉ាទូកកូរ បន្ទាប់ដួសបបរដាក់ចានឲ្យសមាជិកកងដែលនៅឈរតម្រង់ជួរ។ នៅថ្ងៃមួយ អង្គការបានដឹកពោតទៅឲ្យប្រជាជននៅការដ្ឋាននៅឆ្ន័ត្រ ពេលនោះ ប្រធានកងចល័តបានចាត់តាំងសមាជិកកង៤នាក់ ទៅជញ្ជូនពោតចេញពីឡានទៅដាក់ក្នុងរោងបាយរួម។ ដោយសារស្រេកឃ្លានខ្លាំងពេក ខ្ញុំនិងសមមិត្ត ឃឹម បានលួចពោតម្នាក់មួយផ្លែហូប។

ខ្ញុំបន្តធ្វើការងារនៅការដ្ឋាននេះរហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមចូលមកដល់រំដោះ ទើបខ្ញុំបានរួចផុតពីសេចក្តីស្លាប់។ ក្រោយមក ខ្ញុំរៀបការប្រពន្ធឈ្មោះ ណៃ សំអឿន និងមានកូនប្រុសស្រីចំនួន៥នាក់។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានបងប្អូន៤នាក់ បានចូលបម្រើក្នុងបដិវត្តន៍ ដោយម្នាក់ធ្វើពេទ្យឆ្មប ម្នាក់ទៀតធ្វើវេជ្ជបណ្ឌិត និងពីរនាក់ទៀតធ្វើកងទ័ព ក្រោយមកអង្គការយកបងប្អូនខ្ញុំទៅសម្លាប់ចោលនៅក្បាលកោះទាំងអស់។



ជុំ ហាច កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងយប់

*ឈុំ រ៉ា*



ញឹក សាណៃ អាយុ៥៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិល្វាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ញឹក សាណៃ អាយុ៥៣ឆ្នាំ ភេទស្រី មានស្រុកកំណើតនៅភូមិគោញ ឃុំរូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិល្វាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ធុច ញឹក ម្តាយឈ្មោះ ប្រុក ម៉ន។ ម្តាយខ្ញុំបានស្លាប់ជាង១០ឆ្នាំមកហើយ ចំណែកឪពុកខ្ញុំបានស្លាប់នៅក្នុងរបបខ្មែរក្រហម។

នៅក្នុងរបបខ្មែរក្រហមខ្ញុំមានអាយុ៨ឆ្នាំប៉ុណ្ណោះ ហើយនៅពេលនោះប្រជាជនក្នុងភូមិរបស់ខ្ញុំបានបង្កើតជាសហករណ៍ រួចប្រមូលរបស់របរមកដាក់រួម។ ប្រសិនបើប្រជាជនណាមិនយករបស់របរមកដាក់រួម ខ្មែរក្រហមចាត់ទុកអ្នកទាំងនោះថាជាខ្មាំងរបស់អង្គការ។ នៅពេលនោះ គ្រួសាររបស់ខ្ញុំមិនបានរស់នៅជុំគ្នាទេគឺបងប្រុសខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសចូលធ្វើការនៅក្នុងកងចល័ត។ ឪពុកខ្ញុំចូលធ្វើយោធាខាងផ្នែកដឹកជញ្ជូនអង្ករ ដោយខ្មែរក្រហមចាត់តាំងឪពុកខ្ញុំ និងយោធាចំនួន១២នាក់ទៀត ដឹកអង្ករយកទៅឲ្យវៀតណាមដើម្បីដូរយកកាំភ្លើង និងគ្រាប់រំសេវ ហើយដឹកចូលមកខ្មែរវិញ។ ដោយសារឪពុកខ្ញុំខ្លាចវៀតណាមសម្លាប់ ទើបគាត់រត់ពីព្រំប្រទល់ប្រទេសវៀតណាម ស្ថិតនៅក្នុងឃុំរូង ស្រុកមេមត់មកនៅផ្ទះវិញ។

ក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីភូមិគោញមករស់នៅភូមិដើរវិញ ស្រាប់តែមានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីមកសួរនាំប្រធានកងតូចរកឈ្មោះឪពុកខ្ញុំដែលធ្លាប់ធ្វើយោធា។ អ្នកភូមិប្រាប់តាមត្រង់ថា សព្វថ្ងៃឪពុកខ្ញុំរស់នៅភូមិដើរ។ នៅវេលាម៉ោង ៨:០០ យប់ យោធាខ្មែរក្រហមឡើងទៅលើផ្ទះចាប់ឪពុកខ្ញុំចងស្លាបសេកអូសចុះមកដីវិញ។ ម្តាយខ្ញុំបាននៅស្ងៀម និងស្រែកហាមកូនៗកុំឲ្យយំព្រោះខ្លាចខ្មែរក្រហមសម្លាប់ចោលទាំងគ្រួសារ។ ខ្ញុំសួរមីងដែលរស់នៅជិតផ្ទះរបស់ខ្ញុំថា យប់មិញខ្មែរក្រហមចាប់ឪពុកខ្ញុំយកទៅណា? មីងម្នាក់នោះបានប្រាប់ខ្ញុំថា អង្គការយកឪពុកទៅវាយទម្លាក់ចូលក្នុងអណ្តូងនៅដីរីផុង ដោយសារចោទឪពុកខ្ញុំថាក្បត់។

គ្រួសារខ្ញុំរស់នៅភូមិងើបានមួយខែ ខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមិម្ទិច ស្រុកឆ្លូង វិញ។ នៅទីនោះយើងមិនមានអាហារហូបគ្រប់គ្រាន់ទេ បណ្តាលឲ្យយើងស្គមស្គាំង និងមានទឹកមុខស្លេកស្លាំង។ ដោយស្រេកឃ្លានខ្លាំងពេក ខ្ញុំបានទៅរើសយកចុងអង្កនៅជាប់ជាមួយអង្កាម ដែលខាងចុងភៅបោះចោល យកមកលីង និងបុកឲ្យហ្លត់ហូបជំនួសបាយ។ នៅទីនោះ ខ្មែរក្រហមបានចែករបបក្នុងមនុស្សម្នាក់ទទួលបានបបរមួយវែក ទោះហូបឆ្អែត ឬមិនឆ្អែត ក៏អង្គការមិនខ្វាយខ្វល់ដែរ។ នៅដើមឆ្នាំ១៩៧៩ ខ្ញុំបានធ្វើដំណើរពីខេត្តក្រចេះ ត្រឡប់មកកំពង់ចាម ក៏ឃើញកងទ័ពរំដោះ និងវៀតណាមចូលមកដល់។ ខ្ញុំបានសុំឡានកងទ័ពវៀតណាមជិះត្រឡប់មកផ្ទះវិញ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងពីរនាក់ គឺបងទី១) ឈ្មោះរ៉ុន ធ្វើកងទ័ពខ្មែរក្រហម និងបងទី ២) ឈ្មោះក្អែ ធ្វើការនៅកងចល័ត។



ផ្លូវលំនៅក្នុងភូមិល្វាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គក់ ធុន ៖ ទាស់សរសៃដោយសារប្រធានកងប្រើឱ្យកាប់ឧស

*សូ ហាន់*



គក់ ធុន អាយុ៨២ឆ្នាំ រស់នៅភូមិបុស្សស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ គក់ ធុន អាយុ៨២ឆ្នាំ រស់នៅភូមិបុស្សស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ កុយ តុញ និងម្តាយឈ្មោះ គី ព្រម ទាំងមានបងប្អូនបង្កើតចំនួន៦នាក់ ក្នុងនោះមានស្រីចំនួន៤នាក់។ កាលពីដើម ខ្ញុំមិនបានសិក្សារៀនសូត្រដូចកុមារដទៃនៅក្នុងភូមិទេ ដោយសារតែជីវភាពគ្រួសាររបស់ខ្ញុំមានការខ្វះខាត។ ខ្ញុំជួយធ្វើកិច្ចការផ្ទះ និងជួយដកស្ទូងឪពុកម្តាយ។ នៅពេលខ្ញុំអាយុ១៧ឆ្នាំ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ អិន ថន។ កម្មវិធីរៀបការរបស់ខ្ញុំនៅពេលនោះមានរយៈពេល៣យប់៣ថ្ងៃ។

រហូតមកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក៏កើតមានព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ដោយលោក លន់ នល់។ ពេលនោះនៅក្នុងស្រុកភូមិរបស់ខ្ញុំក៏ចាប់ផ្តើមមានការទម្លាក់គ្រាប់បែក។ ថ្ងៃមួយពេល ខ្ញុំនិងគ្រួសាររត់ចូលទៅពួននៅក្នុងត្រង់សេ (លេណដ្ឋាន) ស្រាប់តែមានយន្តហោះមកទម្លាក់ធុងសាំង (គ្រាប់បែកណាប៉ាល់) ចំត្រង់សេ បណ្តាលឲ្យឆាបឆេះ ប៉ុន្តែមិនបណ្តាលឲ្យខ្ញុំនិងគ្រួសាររងរបួសឡើយ។ នៅពេលដែលខ្ញុំលូនចេញពីត្រង់សេ ក៏ឃើញផ្ទះរបស់ខ្ញុំត្រូវភ្លើងឆេះស្ទើរគ្មានសល់ឡើយ។ ខ្ញុំនិងគ្រួសារត្រូវទៅរស់នៅតាមវាលស្រែស្ថិតនៅក្នុងភូមិថ្មសិលា។ ចំណែកប្រជាជនខ្លះដែលរស់នៅខាងលិចវត្តបារាជ ស្ថិតនៅក្នុងភូមិរបស់ខ្ញុំបានស្លាប់ដោយសារការទម្លាក់គ្រាប់បែកនេះ។ មួយរយៈក្រោយមក ខ្ញុំនិងគ្រួសារបានចូលមករស់នៅក្នុងភូមិបុស្សស្បាតវិញ។ នៅចុងឆ្នាំ១៩៧៣ សកម្មភាពនៃការទម្លាក់គ្រាប់បែកនេះបានស្ងប់ស្ងាត់ទៅវិញ។ នៅពេលនោះការរស់នៅរបស់ខ្ញុំ និងប្រជាជនដទៃទៀតលែងមានការភ័យខ្លាចដូចពីមុនទៀតហើយ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ ពេលនោះការរស់នៅរបស់ខ្ញុំក៏ដូចប្រជាជនដទៃទៀតមិនទាន់មានការលំបាកទេ។ រយៈពេលប្រហែលជា

៦ខែក្រោយ ខ្មែរក្រហមចាប់ផ្តើមប្រមូលរបស់របរដាក់ជារបស់រួម ព្រមទាំងបានបង្កើតសហករណ៍ និងរោងបាយរួម ។ នៅពេលនោះ ប្រធានកងប្រើខ្ញុំឲ្យធ្វើការងារ ស្ទូង ដក ច្រូតកាត់ មិនដែលមានពេលឈប់សម្រាកឡើយ។ ក្រៅពីការងារដកស្ទូង ប្រធានកងប្រើខ្ញុំឲ្យបុកស្រូវសម្រាប់ត្រៀមបម្រុងទុកហូបនៅក្នុងរដូវវស្សា។ ចំណែកការហូបចុកវិញ គឺចុងភៅមិនដែលឲ្យខ្ញុំហូបឆ្អែតម្តងណាឡើយ។ ពេលខ្លះ ខ្ញុំបានទៅលួចគាស់ដំឡូងយកមកស្ងោរហូប ដើម្បីបំបាត់ភាពស្រេកឃ្លាន ប៉ុន្តែប្រសិនបើឈ្លបតាមទាន់នឹងយកយើងទៅកសាងមិនខាន។ ពេលវេលាដែលលំបាកបំផុតនៅក្នុងរបបខ្មែរក្រហម គឺពេលដែលខ្ញុំទើបតែសម្រាលកូនរួច ប្រធានកងបានប្រើខ្ញុំឲ្យទៅកាប់ខស និងទូលយកមកទុកនៅរោងបាយ បណ្តាលឲ្យខ្ញុំទាស់សរសៃ និងក្តៅខ្លួនយ៉ាងខ្លាំង។ នៅពេលខ្ញុំក្តៅខ្លួនមិនបាត់ ទើបប្រធានកងបញ្ជូនខ្ញុំទៅព្យាបាលនៅពេទ្យស្ថិតនៅក្នុងភូមិបារាច ហើយពេលខ្ញុំធូរស្បើយគឺត្រូវមកធ្វើការធម្មតាវិញ។ កាលនោះ ខ្ញុំក៏មានជំងឺប្រចាំកាយដែរ គឺជំងឺវិលមុខជារៀងរាល់ថ្ងៃធ្វើឲ្យខ្ញុំមានការលំបាកក្នុងការរស់នៅយ៉ាងខ្លាំង (ប៉ុន្តែក្រោយពេលរបបខ្មែរក្រហមដួលរលំ មានថ្ងៃមួយខ្ញុំបានដើរទៅកាប់ស្ការព្រៃ ស្រាប់តែផ្លែត្នោតជ្រុះមកត្រូវចំចិញ្ចើមរបស់ខ្ញុំ ធ្វើឲ្យជំងឺវិលមុខបាត់ទៅវិញ)។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងប្រជាជននៅក្នុងភូមិត្រូវបានខ្មែរក្រហមជម្លៀសទៅភូមិសៅ្ត ដោយយើងត្រូវដើររយៈពេល១ថ្ងៃ១យប់ទើបទៅដល់ទីនោះ។ ក្រោយមក កងទ័ពរណសិរ្ស និងកងទ័ពវៀតណាមបានចូលមករំដោះ ទើបខ្ញុំនិងប្រជាជនវិលត្រឡប់មកផ្ទះវិញ។ ក្រោយថ្ងៃរំដោះភ្លាម ការរស់នៅរបស់ខ្ញុំនៅមានការលំបាកខ្លះ ព្រោះមិនទាន់មានសម្ភារប្រើប្រាស់ និងនៅខ្វះខាតស្បៀងអាហារ។ នៅពេលនោះ ទ្រព្យសម្បត្តិរបស់ខ្ញុំដែលនៅសេសសល់ពីរបបខ្មែរក្រហម គឺមានតែក្របីពាក្បាលតែប៉ុណ្ណោះ។ ក្រោយមក ខ្ញុំចាប់ផ្តើមរកស៊ីលក់ដូរ និងដើរទៅរុតត្រីនៅភូមិបាបោងយកមកលក់ដើម្បីផ្គត់ផ្គង់ជីវភាពដែលខ្វះខាតនៅក្នុងគ្រួសារ។ សព្វថ្ងៃទោះបីខ្ញុំមានវ័យចាស់ក៏ដោយក៏ខ្ញុំនៅតែធ្វើការបានធម្មតា។



តក់ ធុន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៉ា សុខន ៖ កងចល័តនារី

*រឹម ស្រីស្រស់*



ប៉ា សុខន អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិអង្គគីរ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ា សុខន អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិអង្គគីរ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានម្តាយឈ្មោះ តាំ ខែម គឺជាកសិករ។ គាត់បានស្លាប់ក្នុងឆ្នាំ១៩៧៥ ដោយសារមិនមានអាហារហូបចុកគ្រប់គ្រាន់ពេលខ្មែរក្រហមចូលគ្រប់គ្រង។ ចំណែកឪពុករបស់ខ្ញុំឈ្មោះ ប៉ា ប៉ាក គឺជាគ្រូបង្រៀន។ គាត់បានស្លាប់នៅក្នុងឆ្នាំ១៩៩៤ ដោយសារជំងឺចាស់ជរា។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ហើយខ្ញុំគឺជាកូនច្បងក្នុងគ្រួសារ។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ស៊ុំ សំអឿន ដែលបច្ចុប្បន្នមានអាយុ៦៨ឆ្នាំ។ បន្ទាប់ពីរៀបការរួច ខ្ញុំមានកូនចំនួន៦នាក់ គឺស្រី៣នាក់ និងប្រុស៣នាក់។

កាលពីកុមារភាព ខ្ញុំបានរៀននៅសាលាបឋមសិក្សាអង្គខ្នារ។ រហូតមកដល់ឆ្នាំ១៩៧០ ខ្ញុំទទួលព័ត៌មានថា មានការធ្វើរដ្ឋប្រហារទម្លាក់សម្តេចឪនៅអង្គតាសោម ហើយពេលនោះ ខ្ញុំក៏ឮថាមានការតវ៉ាវាយកម្ទេចផ្ទះថ្មនៅទីនោះទៀតផង។ ទោះបីយ៉ាងណាខ្ញុំនៅរៀនរហូតប្រឡងឌីប្លូមជាប់ ហើយមករៀនបន្តនៅវិទ្យាល័យ ជា ស៊ីម ខេត្តតាកែវ។ នៅឆ្នាំ១៩៧៥ ខ្ញុំបានរៀនចប់ថ្នាក់ទី១ចាស់ ប៉ុន្តែខ្ញុំមិនបានទទួលសញ្ញាបត្រទេ ព្រោះខ្មែរក្រហម កៀរខ្ញុំឲ្យទៅនៅអង្គរបុរី។

នៅឆ្នាំ១៩៧៥ ខ្ញុំរស់នៅជួបជុំគ្រួសារនៅឡើយទេ។ បន្ទាប់មក ម្តាយរបស់ខ្ញុំបានស្លាប់ដោយហូបចុកមិនគ្រប់គ្រាន់។ នៅពេលម្តាយរបស់ខ្ញុំស្លាប់ ខ្មែរក្រហមបានចែកអង្ករចំនួន ១៣កំប៉ុង ឲ្យគ្រួសាររបស់ខ្ញុំដែលមានសមាជិក៩ នាក់សម្រាប់ហូប។ រយៈពេលមួយខែក្រោយមកទៀត ប្អូនប្រុសពៅរបស់ខ្ញុំដែលមានអាយុទើបតែ៣ឆ្នាំ បានស្លាប់ទៀតដោយសារមិនមានទឹកដោះបៅ។ ដោយសារអត់ឃ្លានខ្លាំងពេក នៅពេលយប់ប្អូនរបស់ខ្ញុំបានចេញទៅរើសត្នោតទុំយកមកឲ្យឪពុករបស់ខ្ញុំ។ ឪពុករបស់ខ្ញុំបានបកត្នោតទុំនោះយកតែសាច់ ដើម្បីយកមកចំហុយចែកគ្នាហូប។

ក្រោយមក ខ្មែរក្រហមបានជ្រើសរើសខ្ញុំឲ្យចូលកងចល័តនារី និងចាត់តាំងខ្ញុំឲ្យជីកប្រឡាយនៅក្នុងទឹក។ ប្រឡាយនោះមានឈ្មោះថា ប្រឡាយ៩៧។

កម្មាភិបាលខ្មែរក្រហមបានប្រើខ្ញុំឲ្យយកប៉ែលចូកដីបោះៗឡើងធ្វើជាទំនប់ ដូច្នេះខ្ញុំត្រូវខិតខំប្រឹងប្រែងយ៉ាងខ្លាំង។ នៅរដូវវស្សា ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅស្ទូងនៅលាយបូរ និងនៅថ្មស។ រាល់ពេលដែលខ្ញុំចេញទៅធ្វើការនៅតាមតំបន់ឆ្ងាយៗ ខ្ញុំតែងតែយកថែប (ប្រដាប់សម្រាប់ជ្រកភ្លៀង ដែលមានដំបូលអាចបើកបិទបាន) ទៅតាមរហូត។ ថែបរបស់ខ្ញុំមានបណ្តោយប្រវែង២ម៉ែត្រ និងទទឹង១ម៉ែត្រកន្លះ ដែលអាចដេកបាន២នាក់។ នៅរដូវប្រាំងបន្ទាប់ ខ្មែរក្រហមផ្លាស់ខ្ញុំឲ្យមកជីកប្រឡាយនៅខ្ពបត្របែកម្តង។ នៅពេលនោះ ខ្មែរក្រហមបានបែងចែកដោយក្នុងមួយក្រុមមានមនុស្ស៣នាក់ ត្រូវជីកដីទទឹងនិងបណ្តោយ៣ម៉ែត្រ និងជម្រៅ២ម៉ែត្រ។

នៅឆ្នាំ១៩៧៨ ម្តាយក្មេករបស់ខ្ញុំដែលធ្វើការនៅកងនារីជាមួយខ្ញុំ បានស្នើសុំខ្មែរក្រហមឲ្យខ្ញុំនិងកូនប្រុសរបស់គាត់រៀបការជាមួយគ្នា។ ដូច្នេះខ្មែរក្រហមបានរៀបចំឲ្យខ្ញុំនិងប្តីរបស់ខ្ញុំជាប្តីប្រពន្ធ និងឲ្យខ្ញុំឡើងប្តេជ្ញាជាមួយនឹងប្តីប្រពន្ធជាច្រើនគូទៀត ដែលភាគច្រើនខ្មែរក្រហមរៀបចំឡើងរៀងរាល់ថ្ងៃទី១០ និងថ្ងៃទី២០ នៃខែនីមួយៗ។ នៅពេលនោះ ខ្ញុំក៏សង្កេតឃើញថា មានអ្នកប្រព្រឹត្តខុសសីលធម៌ជាច្រើននាក់ដែរ ដែលភាគច្រើនអ្នកធ្វើការនៅកងចាស់ៗ។ អ្នកខុសសីលធម៌ទាំងអស់នោះ ត្រូវបានខ្មែរក្រហមដាក់ទោសដោយចាត់ឲ្យធ្វើការនៅក្រុមមួយទៀតដែលមានឈ្មោះថា ក្រុមសេរី។ ក្រុមនេះបង្កើតឡើងដើម្បីឲ្យអ្នកខុសសីលធម៌ទាំងអស់ខ្មាស់គេ ហើយអ្នកផ្សេងៗឯទៀតក៏បានដឹងថា ក្រុមសេរីនេះសុទ្ធតែអ្នកខុសសីលធម៌ដែរ។ មេកងរបស់ខ្ញុំឈ្មោះ ប៉ែន សារឿន គឺជាមនុស្សស្លូតបូត និងចិត្តល្អ។

នៅក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ រដ្ឋបានជ្រើសរើសខ្ញុំឲ្យធ្វើជាគ្រូបង្រៀននៅក្នុងភូមិដោយសារខ្វះខាតគ្រូ។ រហូតដល់ឆ្នាំ១៩៨០ ទើបរដ្ឋបង្កើតឲ្យមានការប្រឡងជ្រើសរើសគ្រូបង្រៀន។ នៅពេលខ្ញុំបង្រៀន រដ្ឋបានបើកអង្ករពណ៌ក្រហមនៅអង្គការសោមឲ្យខ្ញុំជារៀងរាល់ខែ។ មួយរយៈក្រោយមកក៏មានការចែកពោត និងស្រូវសាលី១៦គីឡូក្នុងមួយខែ ព្រមទាំងចែកក្រណាត់កាត់ខោអាវថែមទៀត។ រហូតដល់រដ្ឋមានធនធានប្រសើរ ទើបបានផ្តល់ជាប្រាក់ខែក្នុងមួយខែ៩០រៀលដល់ខ្ញុំសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។




ប៉ា សុខន ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៊ុន វ៉ាត ៖ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺ និងអត់អាហារ

ស្បៀង កញ្ញា



ប៊ុន វ៉ាត រស់នៅភូមិត្រពាំងព្រីង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៊ុន វ៉ាត ភេទប្រុស កើតនៅឆ្នាំ១៩៥៨ នៅភូមិត្រពាំងព្រីង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ប៊ុន កេន និងម្តាយឈ្មោះ នាង នូ។ ឪពុកម្តាយខ្ញុំស្លាប់ដោយសារជំងឺ និងអត់អាហារនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់គឺស្រីបីនាក់ និងប្រុសប្រាំនាក់ ហើយខ្ញុំគឺជាកូនទីបួននៅក្នុងគ្រួសារ។ នៅក្នុងចំណោមបងប្អូនរបស់ខ្ញុំ មានចំនួនបីនាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម។

កាលពីកុមារ ខ្ញុំរៀនបានដល់ថ្នាក់ទី១១ ក្នុងសង្គមចាស់ បើប្រៀបធៀបបច្ចុប្បន្នស្មើនឹងថ្នាក់ទី២។ កាលនោះគ្រូបង្រៀនរបស់ខ្ញុំគឺជាព្រះសង្ឃដែលមានព្រះនាម ថ្វាង។ នៅឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀនដោយសារតែប្រទេសជាតិមានសង្គ្រាម។ កាលនោះខ្ញុំអាយុ១២ឆ្នាំ មិនត្រូវបានរដ្ឋាភិបាល លន់ នល់ ជ្រើសឲ្យចូលធ្វើជាទាហានទេ ប៉ុន្តែបងប្រុសរបស់ខ្ញុំម្នាក់ត្រូវបានរដ្ឋាភិបាលជ្រើសរើសគាត់ឲ្យចូលធ្វើជាទាហានដើម្បីបម្រើជាតិ។ ដោយសារតែនៅក្នុងភូមិត្រពាំងព្រីងមិនសូវមានសុវត្ថិភាព ខ្ញុំនិងគ្រួសារបាននាំគ្នាមកជួលផ្ទះស្ថិតនៅក្នុងភូមិភូមិចក សង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ ដើម្បីស្នាក់នៅបណ្តោះអាសន្នរយៈប្រហែលបីឆ្នាំ។ នៅពេលខ្ញុំនិងគ្រួសារមិនមានលុយបង់ថ្លៃផ្ទះ យើងត្រូវបង់ជាស្រូវទៅឲ្យម្ចាស់ផ្ទះ។

នៅវេលាម៉ោង៧ ព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឮខ្មែរក្រហមប្រកាសថា ខ្លួនបានចូលទៅដល់ទីក្រុងភ្នំពេញហើយ ហើយប្រជាជនដែលនៅទីក្រុងភ្នំពេញទាំងអស់ត្រូវទៅរស់នៅទីជនបទវិញ។ ក្រោយមកខ្មែរក្រហមបានជម្លៀសខ្ញុំ គ្រួសារខ្ញុំនិងប្រជាជនឯទៀតចេញពីភូមិពីភូមិចក ទៅភូមិចំប៉ាលើក ស្ថិតនៅក្នុងឃុំតាភេម ស្រុកត្រាំកក់វិញ។ ដំបូងខ្មែរក្រហមមិនទាន់ឲ្យយើងហូបបាយរួមគ្នាទេ គឺបានចែកអង្ករឲ្យប្រជាជនម្នាក់មួយកំប៉ុងយកទៅដាំហូបរៀងខ្លួន។

នៅខែតុលា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងគ្រួសារទៅនៅឃុំបារាយណ៍ ស្រុកទ្រាំង តំបន់

១០៧ វិញ។ ខ្មែរក្រហមបំបែកខ្ញុំចេញពីគ្រួសារ និងឲ្យទៅធ្វើការក្នុងកងចល័ត។ ខ្មែរក្រហមប្រើខ្ញុំឲ្យលើកទំនប់ និងជីកប្រឡាយ។

នៅខែកក្កដា ឆ្នាំ១៩៧៦ ម្តាយរបស់ខ្ញុំស្លាប់ដោយសារអត់អាហារហូប។ នៅខែឧសភា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានប្តូរខ្ញុំឲ្យមកជីកប្រឡាយនៅត្នោតជុំវិញ។ ថ្ងៃមួយមានភ្លៀងធ្លាក់យ៉ាងខ្លាំង ធ្វើឲ្យខ្ញុំមានអារម្មណ៍ឯកោ និងកំសត់យ៉ាងខ្លាំង ព្រោះខ្ញុំមានតែអាវដៃខ្លី និងខោខ្លីមួយសម្រាប់តែប៉ុណ្ណោះ។ នៅពេលយប់ ខ្ញុំមិនមានកន្លែងស្នាក់នៅសមរម្យទេ។ ខ្ញុំដេកនៅតាមការដ្ឋានការងារ ដោយយកស្លឹកត្នោតដែលមានទទឹងប្រវែងមួយហត្ថ (កន្លះម៉ែត្រ) ដែលដេររួច គ្របពីលើមុខកុំឲ្យត្រូវទឹកភ្លៀង។

នៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំបាត់បង់ឪពុកម្នាក់ទៀត។ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ មុនពេលឪពុកខ្ញុំស្លាប់ បងស្រីខ្ញុំតែងតែលួចទៅជួបគាត់ដែលធ្វើការនៅកងដេរសំពត់ជាញឹកញាប់ ប៉ុន្តែពេលបងស្រីទៅមើលគាត់លើកចុងក្រោយ ឪពុករបស់ខ្ញុំបានស្លាប់បាត់ទៅហើយ។ ខ្ញុំនិងបងស្រីឈឺចាប់ និងអាឡោះអាល័យឪពុកខ្ញុំយ៉ាងខ្លាំង។ នៅពេលនោះការហូបចុកមានការខ្វះខាតយ៉ាងខ្លាំង ខ្មែរក្រហមបើកអង្ករទម្ងន់៧ ខាំ សម្រាប់មនុស្ស១០នាក់។ ដោយសារតែខ្ញុំហូបមិនឆ្អែត និងហត់នឿយខ្លាំងពេក ខ្ញុំធ្វើពុតជាឈឺ។ ទោះបីយ៉ាងណា ខ្មែរក្រហមមិនឲ្យខ្ញុំសម្រាកឡើយ គឺបានផ្លាស់ខ្ញុំពីលើកទំនប់ឲ្យទៅដកសំណាបម្តង និងបានកំណត់ឲ្យខ្ញុំដកសំណាបឲ្យបាន៥ដំបក្នុងមួយថ្ងៃ។

មានថ្ងៃមួយ ខ្ញុំដួលសន្លប់នៅការដ្ឋាន ពេលនោះ អ្នកដែលនៅធ្វើការជាមួយខ្ញុំបានសែងខ្ញុំយកទៅព្យាបាលនៅមន្ទីរពេទ្យ។ នៅពេលទៅដល់ពេទ្យ ខ្ញុំបានដឹងខ្លួនឡើងវិញ។ ខ្ញុំមិនចង់ព្យាបាលនៅក្នុងមន្ទីរពេទ្យឡើយ ព្រោះមានអ្នកប្រាប់ខ្ញុំថា នៅពេលអ្នកជំងឺឈឺរ៉ាំរ៉ៃ និងមិនងាយជាសះស្បើយ គ្រូពេទ្យនឹងចាក់ថ្នាំសម្លាប់អ្នកជំងឺនោះ។ មានពេលមួយប្អូនស្រីរបស់ខ្ញុំបានលួចទៅជួបបងស្រីខ្ញុំ ហើយឈ្លបតាមទាន់ក៏ធ្វើទារុណកម្មប្អូនស្រីខ្ញុំ ដោយកប់ប្អូនស្រីខ្ញុំត្រឹមករយៈពេលបីម៉ោង ដើម្បីឲ្យប្អូនស្រីខ្ញុំរាងចាល។ ខ្មែរក្រហមមិនយោគយល់ដល់ក្មេងៗឡើយ គឺឲ្យតែប្រព្រឹត្តខុសវិន័យត្រូវតែទទួលទោស។

មិនយូរប៉ុន្មាន កងទ័ពវៀតណាមបានវាយចូលមក ពេលនោះខ្មែរក្រហមបានកៀរគ្រួសារខ្ញុំនិងប្រជាជនទៅភាគខាងលិចដើម្បីគេចចេញពីកងទ័ពវៀតណាម។ ដោយសារតែប្រជាជនមួយចំនួនមានវ័យចំណាស់មិនអាចបន្តដំណើរទៅមុខបាន យើងក៏នាំគ្នាឈប់សម្រាកនៅវត្តមុន្នីរង្សី ទើបកងទ័ពវៀតណាមទៅស្នាក់ជាប់។ កងទ័ពវៀតណាមប្រាប់យើងឲ្យត្រឡប់មកស្រុកកំណើតរៀងៗខ្លួនវិញ។ ពេលមកដល់ភូមិត្រពាំងព្រីង ផ្ទះរបស់ខ្ញុំត្រូវភ្លើងឆេះអស់ទៅហើយ ដូច្នេះខ្ញុំនិងគ្រួសារបាននាំគ្នាសាងសង់ផ្ទះថ្មីដើម្បីស្នាក់នៅ។ នៅឆ្នាំ១៩៨១ ខ្ញុំបានរៀបការប្រពន្ធ និងបានប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

ប៊ុនវ៉ាត ទទួលប្រអប់អនុស្សាវរីយ៍ពី សៀង កញ្ញា បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ប៉ុល ស៊ីម ៖ អតីតគ្រូបង្រៀន

*ស្រៀង កញ្ញា*



ប៉ុល ស៊ីម សព្វថ្ងៃរស់នៅក្នុងភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ុល ស៊ីម កើតនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៣៥ ហើយបច្ចុប្បន្នរស់នៅក្នុងភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ចំណែកឯទីកន្លែងកំណើតខ្ញុំនៅក្នុងភូមិព្រៃគុយ ក្នុងឃុំលាយបូ។ ខ្ញុំមានឪពុកឈ្មោះ ប៉ុល ហង់ និងម្តាយឈ្មោះ ចាន់បូរ ពីជនាន់ដើមប្រកបរបរធ្វើស្រែចម្ការ និងមានបងប្អូនចំនួន៧ នាក់ គឺប្រុស៤នាក់ និងស្រី៣នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ ជូ សារ៉េង សព្វថ្ងៃអាយុ៨០ឆ្នាំ និងមានកូន៧ នាក់ គឺប្រុស៣នាក់ និងស្រី៤នាក់។

កាលពីកុមារ ខ្ញុំរៀននៅវត្តវិហារខ្ពស់ ដែលមានព្រះសង្ឃគឺជាអ្នកបង្រៀន និងមានសិស្សសរុបប្រមាណ៧០នាក់។ កាលនោះមិនមានបន្ទប់រៀនត្រឹមត្រូវទេ ដូច្នេះព្រះសង្ឃបានយកសាលាឆាន់ក្នុងវត្តធ្វើជាកន្លែងបង្រៀនសិស្ស។ ខ្ញុំរៀននៅវត្តបានរយៈពេល៣ឆ្នាំ ក៏ប្រឡងជាប់សញ្ញាបត្រក្មេងវត្ត។ ការប្រឡងនៅពេលនោះ គឺមានព្រះសង្ឃជាច្រើនអង្គចូលរួមប្រឡងជាមួយគ្នាដែរ ប៉ុន្តែអ្នកដែលប្រឡងជាប់មិនមានគ្នាច្រើនទេ។ បន្ទាប់ពីប្រឡងជាប់សញ្ញាបត្រក្មេងវត្តហើយ ខ្ញុំក៏សម្រេចចិត្តបួសជាព្រះសង្ឃដើម្បីបន្តការសិក្សានៅថ្នាក់ពុទ្ធិកៈ ដែលឥឡូវស្មើនឹងថ្នាក់ទី៧។ ក្រោយមកខ្ញុំក៏ប្រឡងជាប់ និងទទួលបានសញ្ញាបត្របាលីរង ហើយរៀនបន្តរហូតទទួលបានសញ្ញាបត្របំពេញវិជ្ជាទៀត។ ការសិក្សារបស់ខ្ញុំឡើងពីមួយថ្នាក់ទៅមួយថ្នាក់ដោយរលូន ហើយខ្ញុំក៏បន្តការសិក្សានៅសាលាធម្មវិន័យដែលបែកចេញជាបីថ្នាក់ គឺថ្នាក់ត្រី ថ្នាក់ទោ និងថ្នាក់ឯក។ បន្ទាប់ពីបួសបានរយៈពេល១០ឆ្នាំ ខ្ញុំបានប្រឡងជាប់គ្រូបឋម និងបានសឹកវិញ។

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៥៩ ខ្ញុំចេញទៅបង្រៀនដំបូងនៅសាលាបឋមសិក្សា អង្គសិរីមាលា ហៅសាលាសំភ្លី ស្ថិតនៅក្នុងឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ។ បន្ទាប់ពីចេញបង្រៀនបានមួយឆ្នាំ ខ្ញុំក៏រៀបការប្រពន្ធ។ ចំពោះការបង្រៀនមិនមានភាពងាយស្រួលប៉ុន្មាននោះទេ គឺតែងតែជួបឧបសគ្គជាប់ជាប្រចាំ ដូច្នេះខ្ញុំបានអត់ធ្មត់ និងប្រឹងប្រែងបង្រៀនយ៉ាងណាឲ្យសិស្សទទួលចំណេះដឹង។ កាលនោះ រដ្ឋាភិបាលបើកប្រាក់ខែគ្រូបង្រៀនឲ្យខ្ញុំ

ចំនួន១៥០០រៀលក្នុងមួយខែ ក៏ប៉ុន្តែដោយសារទឹកដីស្រុកកោះអណ្តែតជាទឹកដីដែលងាយនឹងកើតជំងឺគ្រុនចាញ់ ដូច្នេះមិនសូវមានអ្នកចង់ទៅបង្រៀននៅទីនោះទេ ដូច្នេះរដ្ឋក៏បានថែមចំនួន៤០០រៀលទៀតសម្រាប់លើកទឹកចិត្តចំពោះអ្នកដែលស្ម័គ្រចិត្តទៅបង្រៀននៅទីនោះ។

កាលសម័យនោះ ខ្ញុំមានកង់មួយគ្រឿងសម្រាប់ជិះមកលេងផ្ទះ និងជិះទៅបង្រៀន។ បន្ទាប់មក ខ្ញុំសន្សំប្រាក់ខែបាន ហើយយកទៅទិញម៉ូតូមួយគ្រឿងក្នុងតម្លៃ ៤០,០០០រៀល។ ដំបូងខ្ញុំមិនចេះជិះម៉ូតូទេ ប៉ុន្តែដោយសារចិត្តចង់បានម៉ូតូក៏ព្យាយាមរៀនជិះរហូតដល់ចេះស្ទាត់។ នៅពេលខ្ញុំធ្វើជាគ្រូបង្រៀន ខ្ញុំស្នាក់នៅផ្ទះឪពុកធម៌របស់ខ្ញុំ។ គាត់ស្រឡាញ់ខ្ញុំណាស់ ដោយចាត់ទុកខ្ញុំដូចជាកូនបង្កើតរបស់គាត់ ដូច្នេះខ្ញុំមិនចំណាយប្រាក់ឡើយក្នុងការស្នាក់នៅ។

ក្រោយពីខ្ញុំបង្រៀននៅសាលាបឋមសិក្សា អង្គសិរីមាលា ក្នុងស្រុកកោះអណ្តែត បានរយៈពេល ១១ឆ្នាំ ខ្ញុំក៏សុំក្រសួងផ្ទេរមកបង្រៀននៅសាលាស្ថិតនៅក្នុងឃុំបារាយណ៍ ស្រុកទ្រាំង ខេត្តតាកែវវិញ។ មូលហេតុដែលខ្ញុំសុំផ្លាស់ប្តូរសាលាបង្រៀន ដោយសារខ្ញុំនិងប្រពន្ធមានផ្ទះនៅក្បែរទីរួមខេត្តមួយខ្នង ដូច្នេះងាយស្រួលធ្វើដំណើរមកផ្ទះ និងរស់នៅក្បែរគ្រួសារ។

រយៈពេលមួយឆ្នាំបន្ទាប់ពីខ្ញុំផ្លាស់មកបង្រៀននៅឃុំបារាយណ៍ ក៏មានការទម្លាក់គ្រាប់បែកនៅម្តុំផ្ទះរបស់ខ្ញុំ ប៉ុន្តែមិនមានអ្នកស្លាប់ទេ។ ខ្ញុំភិតភ័យខ្លាំងណាស់ក៏បញ្ជូនប្រពន្ធរបស់ខ្ញុំឲ្យទៅរស់នៅក្រុងភ្នំពេញ ព្រោះខ្ញុំមានបងប្អូននៅទីនោះ។ ក្រោយមកបានខ្ញុំទៅតាមប្រពន្ធរបស់ខ្ញុំនៅភ្នំពេញ ដោយខ្ញុំមានអាជីពជាគ្រូបង្រៀនដដែល។ ខ្ញុំបង្រៀននៅសាលាបឋមសិក្សាអូរបែកក្អម សង្កាត់១១ ក្នុងក្រុងភ្នំពេញ ហើយកាលនោះខ្ញុំមានកូន៤នាក់។

ចូលមកដល់ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលមកទីក្រុងភ្នំពេញ ហើយនិយាយឃោសនាទៅកាន់ប្រជាជនថា «អ្នកណានៅខេត្តណា នាំគ្នាទៅខេត្តហ្នឹងវិញចុះ»។ បន្ទាប់ពីខ្ញុំឮការឃោសនានេះ ខ្ញុំក៏នាំប្រពន្ធកូន និងប្រមូលរបស់របរដែលចាំបាច់ដាក់តាមខ្លួន។ នៅតាមផ្លូវខ្ញុំឃើញសាកសពជាច្រើននាក់ ដែលភាគច្រើនគឺជាទាហាន។ ខ្ញុំនិងគ្រួសារធ្វើដំណើរដោយថ្មើរជើងពីភ្នំពេញមកខេត្តតាកែវ ដោយចំណាយពេល៤ថ្ងៃ។ ខ្ញុំមកដល់សាលាដើមចំបក់ ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំដេរស្លឹកត្នោតដើម្បីចែកឲ្យប្រជាជនធ្វើថែប (ផ្ទាំងសម្រាប់បាំងថ្ងៃភ្លៀង)។ ចំណែកឯប្រពន្ធ និងកូនរបស់ខ្ញុំ ខ្មែរក្រហមចាត់តាំងឲ្យទៅរកជី និងលាយជីសម្រាប់យកទៅដាក់តាមស្រែ។ មេកងរបស់ខ្ញុំមិនចេះអក្សរទេ ដូច្នេះរាល់ពេលដែលថ្នាក់លើផ្ញើសំបុត្រមកគាត់ម្តងៗ គាត់តែងតែប្រើមនុស្សឲ្យមកហៅខ្ញុំទៅជួយអានឲ្យគាត់ស្តាប់។

ក្រោយមកក៏មានការលេចឮដំណឹងពីប្រជាជនដែលរស់នៅក្បែរខាងថា ខ្ញុំគឺជាអតីតគ្រូបង្រៀន។ បន្ទាប់មក កម្មាភិបាលខ្មែរក្រហមតាមសួររកឈ្មោះខ្ញុំ ប៉ុន្តែដោយសារខ្ញុំដឹងមុននៅពេលដែលកម្មាភិបាលខ្មែរក្រហមដើរមករកឈ្មោះខ្ញុំ ខ្ញុំក៏ប្រាប់ទៅកម្មាភិបាលខ្មែរក្រហមវិញថា ខ្ញុំមិនមែនឈ្មោះ ប៉ុល ស៊ឹម ទេ គឺខ្ញុំឈ្មោះ តាជ។ ខ្ញុំបានរួចផុតពីការតាមដានប្រវត្តិរូបនៅពេលនោះ។ បន្ទាប់មកប្រធានកងប្រើខ្ញុំឲ្យទៅនៅក្នុងកងភ្ជួរវិញ។ ខ្ញុំចាប់ផ្តើមធ្លាក់ខ្លួនស្គមស្គាំងដោយសារតែមិនមានអាហារហូប និងធ្វើការងារធ្ងន់ៗ។ ខ្ញុំធ្វើការនៅក្នុងកងភ្ជួររហូតដល់កងទ័ពស្ម័គ្រចិត្តវៀតណាមចូលមករំដោះ។ នៅពេលប្រទេសជាតិមានសន្តិភាពហើយ ខ្ញុំបានកៀរគរកុមារមកចូលរៀនវិញ។ ដំបូងខ្ញុំប្រមូលបានសិស្សតែមួយថ្នាក់ប៉ុណ្ណោះ ក្រោយមកក៏មានសិស្សចូលរៀនកាន់តែច្រើន ហើយកើនរហូតដល់ទៅ២៨ថ្នាក់។ ដូច្នេះខ្ញុំក៏បានរើសអ្នកដែលប្រឡងជាប់ឌីប្លូមឲ្យមកធ្វើជាគ្រូបង្រៀន ហើយខ្ញុំក៏បានក្លាយជានាយកវិទ្យាល័យរហូតដល់ខ្ញុំចូលនិវត្ត។

# ជាសះស្បើយពីជំងឺដោយសារលេបថ្នាំអាចម៍ទន្សាយនិងទឹកត្នោតជូរ

**ចាន់ ទីន**



ប៉ែន ស៊ិន អាយុ៧៨ឆ្នាំ សព្វថ្ងៃគឺជាជំនួយការរដ្ឋបាលក្នុងសាលាឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ែន ស៊ិន អាយុ៧៨ឆ្នាំ មានស្រុកកំណើតនៅភូមិស្លា ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិបឹង ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានបងប្អូនប្រាំបីនាក់ គឺស្រីបួននាក់ និងប្រុសបីនាក់។ ខ្ញុំមានប្រពន្ធឈ្មោះ សែម យី អាយុ៧៥ឆ្នាំ និងមានកូនប្រាំនាក់ គឺស្រីបួននាក់ និងប្រុសម្នាក់។

នៅឆ្នាំ១៩៥១ កាលខ្ញុំនៅកុមារ តារបស់ខ្ញុំឈ្មោះ ណុប ជា មានតួនាទីជាមេឃុំលាយបូរ បានយកខ្ញុំទៅកន្លែងធ្វើការរបស់គាត់នៅសាលាឃុំរាល់ថ្ងៃ។ លុះខ្ញុំអាយុ៧ឆ្នាំ តារបស់ខ្ញុំបានបញ្ជូនខ្ញុំឱ្យទៅរៀននៅសាលាបឋមសិក្សាអង្គតាសោម។ នៅឆ្នាំ១៩៦២ សហរដ្ឋអាមេរិកបានសាងសង់សាលានៅអង្គតាសោមមួយមានឈ្មោះថា សាលាគំរូអង្គតាសោម។ សាលាគំរូអង្គតាសោម មានបង្រៀននូវមុខវិជ្ជាសិល្បៈមួយចំនួន ដូចជា ភ្លេងពិណពាទ្យ និងច្រៀងជាដើម។ នៅក្នុងកាលវិភាគប្រចាំសប្តាហ៍ ខ្ញុំមានមុខវិជ្ជាសិក្សាអំពីសិល្បៈរយៈពេលមួយម៉ោង ដូច្នេះខ្ញុំបានរៀនអំពីភ្លេងខ្មែរ និងច្រៀង។

នៅឆ្នាំ១៩៦៣ ខ្ញុំរៀនដល់ថ្នាក់ទី៧ចាស់ នៅពេលនោះ តារបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ក្រោយមក ខ្ញុំបានឈប់រៀន ហើយត្រឡប់មកធ្វើស្រែចម្ការជាមួយឪពុកម្តាយរបស់ខ្ញុំវិញ។ មកដល់ឆ្នាំ១៩៦៧ ឪពុកម្តាយខ្ញុំបានរៀបចំជំនុំជុំខ្ញុំឱ្យរៀបការជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំ។ បន្ទាប់ពីរៀបការរួច ខ្ញុំបានប្រកបរបរជាអ្នករត់រ៉ឺម៉ក។

នៅឆ្នាំ១៩៧០ ខ្មែរក្រហមកៀរប្រជាជនប្រុសៗនៅក្នុងភូមិស្លា មកធ្វើបាតុកម្មប្រឆាំងនឹងរបប លន់ នល់ និងដុតបញ្ជីនិងឯកសារនៅសាលាស្រុកត្រាំកក់ ប៉ុន្តែខ្មែរក្រហមមិនបានកៀរខ្ញុំឡើយ ព្រោះខ្ញុំផ្លាស់មកនៅភូមិបឹងជាប់នឹងក្រុងតាកែវ។

មិនយូរប៉ុន្មាន រដ្ឋាភិបាល លន់ នល់ បានបញ្ជូនទាហានចំនួន៣ ឡាន មកពីខេត្តកំពង់ធំ ដោយក្នុងមួយ ឡានផ្ទុកទាហានចំនួន៤០ទៅ៥០នាក់ ដើម្បីមក

ប្រយុទ្ធតទល់នឹងកម្លាំងខ្មែរក្រហមដែលបោះទីតាំងក្នុងភូមិព្រៃគុយ។ ទាហានដែលបញ្ជូនមកពីខេត្តកំពង់ធំបានស្លាប់ទាំងអស់ ដោយសារខ្មែរក្រហមបានលបផ្សាំងគ្រាប់បែកពីលើដើមឈើត្រូវចំ ឡានទៗ

នៅឆ្នាំ១៩៧៣ ខ្ញុំចូលធ្វើទាហាន លន់ នល់ ដើម្បីយកប្រាក់ខែចិញ្ចឹមគ្រួសារ។ នៅចុងឆ្នាំ១៩៧៤ ខ្ញុំបានឡើងមកវាយតទល់នឹងខ្មែរក្រហមនៅខ្សែត្រៀមក្នុងទីក្រុងភ្នំពេញអស់រយៈពេល៣ខែ។ នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ ហើយខ្ញុំក៏វិលត្រឡប់មកជួបជុំគ្រួសារនៅខេត្តតាកែវវិញ។ នៅពេលធ្វើដំណើរតាមផ្លូវ ចោរបានលួចយកវ៉ាលិសដាក់ខោអាវ និងលុយមួយចំនួនដែលខ្ញុំសន្សំបានពីប្រាក់ខែទាហានរបស់ខ្ញុំ។ លុះខ្ញុំមកដល់ភូមិ ខ្មែរក្រហមបានបញ្ជូនខ្ញុំ និងគ្រួសាររបស់ខ្ញុំ ព្រមទាំងប្រជាជនជម្លៀសជាច្រើនគ្រួសារទៀត ទៅជុំគ្នានៅក្នុងវត្តចម្ប៉ា។

នៅទីនោះខ្មែរក្រហមបានប្រកាសថា អ្នកដែលធ្លាប់ធ្វើជា ប៉ូលីស ទាហាន មន្ត្រីរដ្ឋការ និងការងារផ្សេងទៀតត្រូវមកចុះឈ្មោះ ដើម្បីទៅធ្វើការងាររបស់ខ្លួនវិញ ប៉ុន្តែតាមពិតខ្មែរក្រហមបានបញ្ជូនអ្នកទាំងនោះទៅសម្លាប់ចោលទាំងអស់។ ខ្ញុំព្យាយាមលាក់ប្រវត្តិ ហើយដោយសារខ្មែរក្រហមមិនបានស៊ើបសួរប្រវត្តិរូបរបស់ខ្ញុំ ទើបខ្ញុំបានរួចខ្លួន។ បន្ទាប់មក ខ្មែរក្រហមបានបញ្ជូនខ្ញុំ និងក្រុមគ្រួសារទៅធ្វើការនៅឃុំបារាយណ៍។ មុនដំបូងខ្មែរក្រហមឲ្យខ្ញុំ និងមនុស្សពីរនាក់ទៀត ឃ្វាលគោចំនួន ៤០នឹមរយៈពេល៥ខែ។ នៅពេលខ្មែរក្រហមឃើញខ្ញុំមានកម្លាំងមាំមួនហើយ ក៏បញ្ជូនខ្ញុំឲ្យទៅដាំដំណាំវិញ។ ខ្ញុំដាំដំណាំបានបីថ្ងៃក៏ធ្លាក់ខ្លួនឈឺ ទើបខ្មែរក្រហមបញ្ជូនខ្ញុំទៅព្យាបាលនៅពេទ្យភូមិជ្រោយសំរោង។ ពេទ្យបានឲ្យថ្នាំគ្រាប់អាចម៍ទន្សាយ និងទឹកត្នោតជូរឲ្យខ្ញុំផឹកដើម្បីបំបាត់ក្តៅក្នុងខ្លួន។

ខ្ញុំបានលេបថ្នាំអាចទន្សាយ និងផឹកទឹកត្នោតជូរអស់៥ថ្ងៃលបណ្តាលឲ្យខ្ញុំស្រវឹង និងដេកលក់។ ក្រោយពីខ្ញុំដឹងខ្លួនឡើងវិញ ស្រាប់តែខ្ញុំជាសះស្បើយពីជំងឺ។ បន្ទាប់មក ប្រធានកងឈ្មោះ វើង ចង់យកខ្ញុំទៅនៅខាងដាំដំណាំនៅព្រៃផ្អេរវិញ ប៉ុន្តែពេលនោះប្រធានកងឈ្មោះ ហៃ នៅឃុំបារាយណ៍មកប្រាប់ខ្ញុំថាមិនចាំបាច់ទៅព្រៃផ្អេរទេ គឺនៅជាមួយគាត់នៅបារាយណ៍ហ្នឹងហើយ ចាំគាត់ជួយនិយាយជាមួយប្រធានកងវើង ព្រោះ វើង គឺជាមិត្តភក្តិរបស់គាត់។ ចាប់តាំងពីពេលនោះមក ខ្ញុំនៅធ្វើការជាមួយឈ្មោះ ហៃ។ ពេលនោះ ខ្ញុំនៅខាងសេដ្ឋកិច្ច និងត្រូវដឹកបន្លែ ដឹកស្ករ ត្រីសាច់ និងដឹកប្រេងកាតទៅឲ្យប្រជាជននៅសហករណ៍ ដោយក្នុងមួយគ្រួសារទទួលបានប្រេងកាត២លីត្រ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលមក ពេលនោះខ្ញុំនិងគ្រួសារ បានរត់ភៀសខ្លួនទៅតាមឪពុករបស់ខ្ញុំទៅដល់ភ្នំវាយចាប។ ពេលទៅដល់ទីនោះ ខ្ញុំនិងគ្រួសារបានជួបកងទ័ពវៀតណាម ទើបកងទ័ពវៀតណាមប្រាប់ខ្ញុំ និងក្រុមគ្រួសារឲ្យវិលត្រឡប់មកស្រុកកំណើតវិញ។ សព្វថ្ងៃខ្ញុំមានតួនាទីជាជំនួយការរដ្ឋបាល ក្នុងសាលាឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។



ប៉ែន ស៊ិន ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដោយសារខ្វះខាតអាហារ ម្ដាយខ្ញុំ
## ដាច់ចិត្តលួចបេះផ្លែននោងដែលដាំជាប់សំយាបផ្ទះស្មោរឱ្យខ្ញុំហូប

*សូ ហាន់*



*ប្រិន ណយ ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ផុន ស្រីពេជ្រ បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ប្រិន ណយ កើតនៅភូមិបុស្សរីស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ម៉ម ប្រិន និងម្ដាយឈ្មោះ ជា ណាន់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ គឺស្រី៣នាក់ និងប្រុស៣នាក់។

កាលនៅវ័យកុមារ ខ្ញុំមិនបានសិក្សារៀនសូត្រជ្រៅជ្រះទេ គឺរៀនបានត្រឹមថ្នាក់ទី១១ពីសង្គមចាស់ប៉ុណ្ណោះ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ បន្ទាប់ពីមានព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ខ្ញុំនិងគ្រួសាររស់នៅមិនបានសុខស្រួលឡើយ។ យើងរត់ចូលពួនក្នុងត្រង់សេ (លេណដ្ឋាន) ជាញឹកញាប់ ហើយជួនកាលយើងចាកចេញពីភូមិរបស់យើងទៅរស់នៅភូមិផ្សេងទៀត ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែក។

បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំធ្វើការងារនៅក្នុងកងស្ទូង ប៉ុន្តែខ្ញុំមិនដែលទទួលបានរបបហូបចុក

គ្រប់គ្រាន់ឡើយ។ ដោយសារតែការហូបចុកខ្វះខាត ម្ដាយរបស់ខ្ញុំបានដាច់ចិត្តលួចបេះផ្លែននោងដែលដាំនៅជាប់សំយាបផ្ទះមកស្ងោរឲ្យខ្ញុំហូប។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងក្រុមគ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិ និងឲ្យធ្វើដំណើរទៅកាន់ភូមិស្វាយកាប ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ក្រោយមក ខ្ញុំនិងគ្រួសារបានវិលត្រឡប់មករស់នៅភូមិកំណើតវិញ។ ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ការរស់នៅរបស់ខ្ញុំនិងគ្រួសារនៅជួបការលំបាកខ្វះ ព្រោះសម្ភារគោក្របីសម្រាប់ប្រើប្រាស់ធ្វើស្រែចម្ការបានបាត់បង់អស់ដោយសាររបបខ្មែរក្រហម។ បន្ទាប់មកយើងចាប់ផ្ដើមធ្វើស្រែប្រវាស់ដៃគ្នាទៅវិញទៅមកដើម្បីយកផលស្រូវមកចែកគ្នាហូប។

ចាប់តាំងពីឆ្នាំ១៩៨០មក ខ្ញុំបានចិញ្ចឹមសត្វ និងដាំដំណាំបន្ទាប់បន្សំ ទើបធ្វើឲ្យជីវភាព និងការហូបចុករបស់ខ្ញុំបានប្រសើរឡើង។ មកដល់ពេលនេះ ខ្ញុំមានជីវភាពសមរម្យ និងមិនលំបាកដូចកាលខ្ញុំរស់នៅក្នុងរបបខ្មែរក្រហមឡើយ។ ដោយសារតែខ្ញុំធ្លាប់រស់នៅឆ្លងកាត់ទុក្ខលំបាក ដូច្នេះខ្ញុំតែងតែយករឿងរ៉ាវរបស់ខ្ញុំនិទានឲ្យកូនចៅរបស់ខ្ញុំស្ដាប់ជាញឹកញាប់ ដើម្បីឲ្យកូននិងចៅរបស់ខ្ញុំបានដឹងពីប្រវត្តិសាស្ត្រកាលពីរបបខ្មែរក្រហម។ មានពេលខ្លះខ្ញុំក៏យល់សុបិនឃើញរឿងរ៉ាវលំបាកវេទនារបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហមដែរ ធ្វើឲ្យខ្ញុំមានការភ័យរន្ធត់យ៉ាងខ្លាំង។



ប្រិន ណយ សព្វថ្ងៃរស់នៅភូមិបុស្សឫស្សីបាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្លែននោង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផុន ដុំ ៖ កងចល័តក្នុងរបបខ្មែរក្រហម

*ភា រស្មី*



*ផុន ដុំ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ ថុន ស្រីពេជ្រ បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ផុន ដុំ អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិបុស្សឫស្សីត្បារតាឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានស្រុកកំណើតនៅភូមិពោន ឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ នៅសម័យខ្មែរក្រហម អង្គការបានប្តូរឈ្មោះពីភូមិពោន ទៅភូមិគ្រោក ក្នុងឃុំទឹកថ្លាវិញ។

នៅក្នុងរបប លន់ នល់ ខ្ញុំរៀននៅក្រោមផ្ទះរបស់តា ពៅ ដែលជាគ្រូបង្រៀនក្មេងតូចៗនៅក្នុងភូមិ។ ក្រោយមក នៅក្នុងភូមិរបស់ខ្ញុំចាប់ផ្តើមមានការទម្លាក់គ្រាប់ ដូច្នេះគ្រួសាររបស់ខ្ញុំតែងតែរត់ទៅលាក់ខ្លួននៅផ្ទះតារបស់ខ្ញុំស្ថិតនៅក្នុងភូមិថ្មី។ បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះ នៅឆ្នាំ១៩៧៥ អង្គការចាត់តាំងឲ្យក្រុមកុមារដូចជាខ្ញុំទៅធ្វើការលើកប្រព័ន្ធភ្លឺស្រែជាមួយចាស់ៗនៅក្បែរភូមិ។ នៅពេលឈប់សម្រាកពីការងារថ្ងៃត្រង់អង្គការបានឲ្យគ្រូទៅបង្រៀនខ្ញុំនិងកុមារទាំងអស់នៅក្រោមម្លប់ឈើ។

នៅឆ្នាំ១៩៧៦ អង្គការបានបញ្ជូនខ្ញុំឲ្យទៅលើកអាងស្តុបទឹកនៅស្ពានីយ៍អ្នកណ្តាល ជាមួយយុវជនផ្សេងទៀត។ ការហូបអាហារនៅក្នុងកងចល័តមិនគ្រប់គ្រាន់ទេ ព្រោះត្រូវហូបអាហាររួមតាមក្រុមដែលមានសមាជិកច្រើន។ បន្ទាប់ពីបញ្ចប់ការងារលើក

អាងស្តុបទឹក អង្គការបានចាត់តាំងឲ្យខ្ញុំយាមល្បាតក្របី នៅអូរកណ្តាល រហូតដល់ខែសីហា ឆ្នាំ១៩៧៦។ នៅទីនោះ ខ្ញុំឈឺរាកមួលធ្ងន់ធ្ងរ ដូច្នេះអង្គការក៏បញ្ជូនខ្ញុំឲ្យមកព្យាបាលនៅមន្ទីរពេទ្យក្នុងភូមិវិញ។ ជំងឺរបស់ខ្ញុំមិនបានធូរស្រាលទេ ប៉ុន្តែដោយសារតែពេទ្យចាក់ថ្នាំឲ្យខ្ញុំមានការឈឺខ្លាំងពេក ទើបខ្ញុំសុំពេទ្យត្រឡប់មកផ្ទះវិញ។ នៅពេលមកដល់ផ្ទះ ឪពុករបស់ខ្ញុំបានដើររកបុសឈើយកមកដាំរំងាស់និងដាំលាយជាមួយទឹកឲ្យខ្ញុំផឹក ទើបខ្ញុំបានធូរស្បើយពីជំងឺ។

ចូលមកដល់រដូវវស្សា អង្គការប្រើខ្ញុំឲ្យទៅសែងដីលេខ១យកទៅស្រែ រួចយកសំណាបមកជ្រលក់ជាមួយដីនោះមុននឹងស្ទូងដើម្បីឲ្យសំណាបដុះលូតលាស់ល្អ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំធ្វើការងារជាច្រើនដូចជា ដើរប្រមូលជី ដក ស្ទូង នៅក្នុងរដូវវស្សា ហើយរដូវប្រាំង ខ្ញុំទៅលើកប្រព័ន្ធភ្លឺស្រែ និងទំនប់នៅកៅទែអំពិលទោល និងខាងក្រោយ។ ពេលខ្ញុំចេញទៅលើកប្រព័ន្ធភ្លឺស្រែ ខ្ញុំហូបអាហារបានគ្រាន់បើជាងពេលនៅធ្វើការនៅអូរកណ្តាល។

នៅដើមខែមករា ឆ្នាំ១៩៧៩ អង្គការបានជម្លៀសខ្ញុំទៅភូមិស្តៅ ហើយពីរថ្ងៃបន្ទាប់មកទើបខ្ញុំត្រឡប់មកផ្ទះវិញ។ នៅខែផល្គុន ឆ្នាំ១៩៧៩ ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំនៅភូមិបុស្សឫស្សាត ហើយក៏ស្នើសុំរបបដីស្រែពីរដ្ឋសម្រាប់ធ្វើស្រែរហូតមកដល់សព្វថ្ងៃ។ បច្ចុប្បន្ន ខ្ញុំមានកូន៤នាក់ ប្រុស៣នាក់។ ខ្ញុំតែងតែយករឿងរ៉ាវទាំងអស់ដែលខ្ញុំបានឆ្លងកាត់សម័យខ្មែរក្រហមប្រាប់ទៅកូនៗរបស់ខ្ញុំ។



ផ្ទះរបស់ ផុន ជុំ ស្ថិតនៅក្នុងភូមិបុស្សឫស្សាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យង់ សាលូត ៖ កងដឹកប្រឡាយនៅក្នុងរបបខ្មែរក្រហម

ថុន ស្រីពេជ្រ



យង់ សាលូត អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិឫស្សីស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យង់ សាលូត អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិឫស្សីស្បាត ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ កាលនៅពីតូច ខ្ញុំបានរៀននៅសាលាវត្តបារាច។ ខ្ញុំបានឈប់រៀនត្រឹមថ្នាក់ទី៩អំឡុងពេលកើតមានសង្គ្រាម និងការទម្លាក់គ្រាប់បែក នៅឆ្នាំ១៩៧០។ កាលនោះក្រុមគ្រួសាររបស់ខ្ញុំបានរត់ទៅខាងជើងស្រុកមេសាង ដើម្បីគេចពីការទម្លាក់គ្រាប់បែក និងរថក្រោះរបស់ទាហានធីវគី ឬវៀតណាមខាងត្បូង។ ក្រោយមក ខ្ញុំទទួលដំណឹងថា ខ្មែរក្រហមបានវាយបែកទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ កាលនោះខ្ញុំមានការសោកស្តាយយ៉ាងខ្លាំង ព្រោះមិនឃើញសម្តេច ព្រះនរោត្តម សីហនុ មកដឹកនាំប្រទេសវិញ។

ខ្មែរក្រហមបានបង្កើតជាសហករណ៍ និងរោងបាយរួម ហើយទ្រព្យសម្បត្តិដែលក្រុមគ្រួសាររបស់ខ្ញុំមានដូចជា គោ ក្របី មាស ប្រាក់ ចានឆ្នាំង ដីធ្លី ត្រូវបានប្រមូលមកដាក់ជាសម្បត្តិរួមទាំងអស់។ ចំណែកខ្ញុំត្រូវបានប្រធានកងប្រើឲ្យរែកកណ្តាប់ និងភ្ជួររាស់ដីនៅរដូវវស្សា។ នៅរដូវប្រាំង ខ្ញុំត្រូវបានខ្មែរក្រហមចល័តឲ្យទៅដឹកប្រឡាយនៅតំបន់ផ្សេងៗ។ ខ្ញុំបានទៅដឹកប្រឡាយនៅស្រុកមេសាង និងស្រុកកំចាយមារ ហើយចុងក្រោយ ខ្ញុំទៅដឹកប្រឡាយនៅចាន់ទៃក្បែរព្រំដែនកម្ពុជាវៀតណាម។

ខ្ញុំកម្របានមកលេងផ្ទះណាស់។ ពេលខ្ញុំទៅធ្វើការនៅកន្លែងណា ខ្ញុំគឺត្រូវដេកនៅកន្លែងនោះរហូតដល់ចប់កិច្ចការ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំ។បន្ទាប់ពីខ្ញុំរៀបការរួចចំនួនបីខែ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំទៅកាន់ខេត្តពោធិ៍សាត់។ ខ្ញុំនិងប្រពន្ធបានធ្វើដំណើរទៅអ្នកលឿងរួចឡើងជិះកប៉ាល់បន្តទៅឈប់នៅច្បារអំពៅ ក្រុងភ្នំពេញ។ ខ្ញុំនិងប្រពន្ធសម្រាកនៅភ្នំពេញចំនួនបីយប់ យើងក៏ឡើងជិះរថភ្លើងបន្តទៅកាន់ខេត្តពោធិ៍សាត់។

ខ្ញុំនិងប្រពន្ធបានទៅដល់ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ នៅពេលយប់ដោយមានប្រធានសហករណ៍មកចាំទទួល និងផ្តល់កន្លែងស្នាក់នៅដល់យើង។ ការងាររបស់ខ្ញុំនៅទីនោះគឺច្រូតស្រូវ។ ស្រូវដែលខ្ញុំច្រូតបានទាំងប៉ុន្មាននៅពេលថ្ងៃ គឺត្រូវបោកបែនឲ្យរួចរាល់នៅពេលយប់ ព្រោះខ្មែរក្រហមប្រញាប់ដឹកស្រូវទាំងអស់នោះ ឡើងទៅលើភ្នំដើម្បីស្តុកទុកពេលធ្វើសង្គ្រាម។

បន្ទាប់ពីកងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជារំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ស្រូវនៅតំបន់របស់ខ្ញុំរស់នៅ ក៏ច្រូតរួចរាល់ដែរនៅវេលាម៉ោង១២ថ្ងៃត្រង់។ ខ្មែរក្រហមបាននិយាយថា នឹងធ្វើពិធីជប់លៀងឲ្យប្រជាជនដែលខិតខំបំពេញការងារនៅពេលយប់។ ប៉ុន្តែមិនទាន់បានជប់លៀងផងខ្មែរក្រហមបានរត់ខ្ចាត់ខ្ចាយអស់ បន្ទាប់ពីបានឃើញកងទ័ពស្ម័គ្រចិត្តវៀតណាមវាយសម្រុកចូលមកដល់ខេត្តពោធិ៍សាត់។

ប្រជាជនមួយចំនួនបានរត់ភៀសខ្លួនទៅ នៅជំរំជនភៀសខ្លួនតាមព្រំដែនខ្មែរថៃ ដើម្បីរង់ចាំឱកាសទៅរស់នៅបរទេស។ ចំណែកឯខ្ញុំបានធ្វើដំណើរមកស្រុកកំណើត។ ក្រោយឆ្នាំ១៩៧៩ ខ្ញុំបានចូលធ្វើជាសេនាជនភូមិរហូតដល់ឆ្នាំ១៩៨៥ ទើបខ្ញុំផ្លាស់មកធ្វើជាអនុភូមិរហូតមកដល់សព្វថ្ងៃ។



យង់ សាលូត ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ សូ ហាន់ និង ផុន ស្រីពេជ្រ បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។
( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )







# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។







មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។




តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។







ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org







សូមអរគុណ!

# វេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

*ហ៊ាន ពិសី*



យុវជនចំនួន១២នាក់ មកពីវិទ្យាល័យអន្លង់វែង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពី “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” ដោយមានការចូលរួមពីយុវជនចំនួន ១២នាក់ មកពីវិទ្យាល័យអន្លង់វែង។ វេទិកានេះធ្វើក្នុងគោលបំណង “លើកកម្ពស់លើការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងអត្ថជិនុំជម្រះវិសាមញ្ញក្នុងតុលាការខ្មែរក្រហម”។

ថ្នាក់រៀននេះ ចាប់ផ្តើមឡើងដោយឲ្យសិស្សានុសិស្សធ្វើការគិតនូវសំណួរមួយដែលខ្លួនចង់ដឹងបំផុតអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីជាផ្នែកមួយនៅក្នុងការយកមកពិភាក្សា។ សំណួរទី១) តើរបបខ្មែរក្រហមបង្កើតឡើងក្នុងគោលបំណងអ្វី? ទី២) មូលហេតុអ្វីដែលនាំឲ្យកើតអំពីប្រល័យពូជសាសន៍? ទី៣) តើរបបកម្ពុជាប្រជាធិបតេយ្យមានផលប៉ះពាល់អ្វីខ្លះដល់ប្រជាជន និងសង្គមជាតិ។ ទី៤) រាល់សមិទ្ធផលកសិកម្មដែលប្រមូលផលបាននៅសម័យនោះ ខ្មែរក្រហមបញ្ជូនទៅណា ហេតុអ្វីធ្វើឲ្យប្រជាជនជួបការអត់ឃ្លាន? ទី៥) របបកម្ពុជាប្រជាធិបតេយ្យ ផ្តោតទៅលើវិស័យអ្វីដែលសំខាន់

ជាងគេ? ទី៦) តើមេដឹកនាំសម័យខ្មែរក្រហមបានដឹងអំពីការប្រព្រឹត្តអំពើឃោរឃៅមកលើប្រជាជនដែរឬទេ? ទី៧) តើការរៀបការប្រជាជននៅសម័យនោះរៀបចំឡើងយ៉ាងដូចម្តេច? ទី៨) ហេតុអ្វីបានជាសម័យនោះខ្មែរក្រហមសម្លាប់ខ្មែរគ្នាឯង?

បន្ទាប់មកបណ្ឌិត លី សុខឃាង បានធ្វើការបង្ហាញអំពីរបៀបនៃការចេះប្រើប្រាស់ឯកសារ ក៏ដូចជាការស្វែងរកចម្លើយពីក្នុងសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ វិធីនេះបានជំរុញឲ្យសិស្សអាចធ្វើការងារបានយ៉ាងរហ័សក្លាហាន និងអាចធ្វើការបញ្ចេញមតិនូវអ្វីដែលខ្លួនបានគិត និងស្វែងយល់ អំពីរឿងរ៉ាវអតីតកាលដែលបានកើតឡើងកាលពី៤០ឆ្នាំមុន។ របបខ្មែរក្រហមបានអនុវត្តគោលនយោបាយ និងមនោគមវិជ្ជាបែបជ្រុលនិយម ធ្វើឲ្យមនុស្សជិត២លាននាក់បានស្លាប់ ដោយការបង្ខំឲ្យធ្វើការធ្ងន់ហួសកម្លាំង បង្អត់អាហារ និងការធ្វើទារុណកម្មរហូតដល់ស្លាប់។ អំពើទាំងអស់នេះបានឆ្លុះបញ្ចាំងឲ្យឃើញអំពីការស្អប់ខ្ពើម ការរើសអើងរហូតឈានទៅការប្រព្រឹត្តនូវអំពើប្រល័យពូជសាសន៍ ដែលជាការបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែកទៅលើក្រុមពូជសាសន៍ សាសនា ជនជាតិ និងជាតិពន្ធុ។

ក្នុងចំណោមសិស្សទាំង១២នាក់មានសិស្សម្នាក់យល់ឃើញថា "យុវជនជំនាន់ក្រោយមិនថារស់នៅអន្លង់វែង ឬក៏ខេត្តណានៃប្រទេសកម្ពុជាទេសុទ្ធតែជាអ្នកដែលមានឪពុកម្តាយ ឬជីដូនជីតា ធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ ដូច្នេះបើមាននរណាម្នាក់ហៅយើងថា ខ្មែរក្រហម យើងពុំគួរខឹងទេ តែយើងត្រូវឆ្លើយតបទៅវិញថា អ្នកដែលរស់រានមានជីវិតក្រោយរបបខ្មែរក្រហមគឺគ្មានកំហុសទេ ព្រោះដំណើរការនៃកាត់ទោសមេដឹកនាំខ្មែរក្រហមបានបញ្ចប់ និងស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនរួចរាល់ហើយ។ បើទោះបីមេដឹកនាំទាំងនោះឆ្លើយបដិសេធថា ខ្លួនមិនបានដឹងរឿងរ៉ាវទាំងអស់នេះក៏ដោយ ព្រោះតុលាការបានរកឃើញភ័ស្តុតាងគ្រប់គ្រាន់ដើម្បីសម្រេចកាត់ទោសមេដឹកនាំទាំងនោះ ក្នុងនាមជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះ









យុវជនចំនួន១២នាក់ មកពីវិទ្យាល័យអន្លង់វែង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ”។

ជាចុងបញ្ចប់នៃកម្មវិធីក៏មានការពន្យល់បង្ហាញពីផែនទី ទីតាំងប្រវត្តិសាស្ត្រទាំង១៨កន្លែង និងគម្រោងផែនការអភិវឌ្ឍន៍នៅក្នុងស្រុកអន្លង់វែង។ ទស្សនវិស័យនេះនឹងប្រែក្លាយអន្លង់វែងដែលជាតំបន់តស៊ូចុងក្រោយបង្អស់របស់ខ្មែរក្រហមឲ្យទៅជាទីតាំងដែលមានសក្តានុពលខ្ពស់ផ្នែកកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។

**ហ៊ីម អ៊ីហុង** ភេទស្រី អាយុ១៨ឆ្នាំ សិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យអន្លង់វែង និយាយថា «យើងមិនអាចទាញពេលវេលាត្រឡប់ក្រោយ ដើម្បីកែបញ្ហាដែលធ្លាប់កើតមាននៅក្នុងរបបឃោរឃៅមួយនេះបានទេ។ អ្វីដែលយើងដែលយើងអាចធ្វើបាន ក្នុងនាមជាយុវជនជំនាន់ក្រោយគឺត្រូវសិក្សាពីប្រវត្តិសាស្ត្រមួយនេះឲ្យច្រើន ព្រោះវាបានឆ្លុះបញ្ចាំងឲ្យយើងឃើញថា ការដឹកនាំបែបកុម្មុយនីស្ត បែបផ្តាច់ការ វាមានផលប៉ះពាល់ណាស់ចំពោះប្រជាជន ក៏ដូចជាសង្គមជាតិ។ ជាក់ស្តែងដូចជាដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបង្កើតឡើងដើម្បីដាក់ទោស ក៏ដូចជាស្វែងរកយុត្តិធម៌ជូនប្រជាជន។ ទោះបីមិនអាចជួយឲ្យអ្នកដែលបាត់ជីវិតស្លាប់ហើយរស់ឡើងវិញ ប៉ុន្តែវាក៏បានស្វែងរកយុត្តិធម៌ និងធ្វើជាគំរូមួយសម្រាប់យុវជនកុំឲ្យដើរតាមគន្លងអតីតកាលខ្មៅងងឹតនេះម្តងទៀត»។

**អៀម បុប្ផា** ភេទស្រី អាយុ១៧ឆ្នាំ សិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យអន្លង់វែង និយាយថា «ការសិក្សាពីប្រវត្តិសាស្ត្រ មានសារសំខាន់ណាស់ក្នុងនាមយើងជាអ្នកជំនាន់ក្រោយ ព្រោះអាចឲ្យយើងដឹងពីការផ្លាស់ប្តូរពីសម័យកាលមួយទៅសម័យកាលមួយទៀត។ ជាពិសេស អាចធ្វើឲ្យយុវជនមានការផ្លាស់ប្តូរផ្នត់គំនិត មានការគិតវែងឆ្ងាយ ជៀសវាងកុំឲ្យកើតមានការរើសអើង ឬស្អប់ខ្ពើមគ្នា ដែលនាំឲ្យកើតមានអំពើប្រល័យពូជសាសន៍បន្តទៀត»។

**ហៀត រតនា** ភេទប្រុស អាយុ១៨ឆ្នាំ សិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យអន្លង់វែង និយាយថា «ខ្ញុំចូលចិត្តរៀនពីប្រវត្តិសាស្ត្រនេះណាស់ ដោយសារតែនៅមានរឿងរ៉ាវជាច្រើនដែលបានបង្រៀនឲ្យយើងដែលជាយុវជនជំនាន់ក្រោយទុកជាគំរូ។ របបនេះបានសម្លាប់ប្រជាជនអស់ជាច្រើន ប៉ុន្តែអ្នកដែលត្រូវជាប់ទោសពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្មនេះមានតែមេដឹកនាំកំពូលប៉ុន្មាននាក់។ សម្រាប់ខ្ញុំគិតថាវាពុំទាន់ស័ក្តិសមនៅឡើយទេដោយសាររឿងនេះនៅមានអ្នកផ្សេងទៀតដែលគួរតែត្រូវបានយកមកកាត់ទោសដែរ»។





យុវជនចំនួន១២នាក់ មកពីវិទ្យាល័យអន្លង់វែង ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” រៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រតិភូមកពីក្រសួងការពារជាតិ ទស្សនកិច្ចពិព័រណ៍ «សុបិនកម្ពុជា»

សោម ប៊ុនថន



នៅព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមប្រតិភូប្រវត្តិសាស្ត្រយោធាចំនួន២០រូប មកពីក្រសួងការពារជាតិ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវសាងសង់វិមានឈ្នះ ឈ្នះ មកទស្សនកិច្ច «ពិព័រណ៍សុបិនកម្ពុជា» ដោយមានការទទួលស្វាគមន៍ ពីឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ជែលដ្រេស (Julio A. Jeldres) អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមប្រតិភូប្រវត្តិសាស្ត្រយោធាចំនួន២០រូប មកពីក្រសួងការពារជាតិ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវសាងសង់វិមានឈ្នះ ឈ្នះ មកទស្សនកិច្ច «ពិព័រណ៍សុបិនកម្ពុជា» ដែលរៀបចំឡើងដោយបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឧទ្ទិសថ្វាយព្រះបរមរាជវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេច



ព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋគម្រប់ខួបព្រះប្រសូត្រ ១០០ ព្រះវស្សា នាសាលមហោស្រពចតុមុខ។

បណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្ទីករីត ដែលបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មានកិត្តិយសសូមធ្វើការរំឭកគម្រប់ខួបមួយរយព្រះវស្សារបស់ព្រះបរមរតនកោដ្ឋ ព្រះបាទ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ (ឆ្នាំ១៩២២-២០២២) ដែលព្រះអង្គបានបូជាអស់ព្រះកម្លាំងកាយចិត្តក្នុងអំឡុងពេលដែលព្រះអង្គគង់នៅមានព្រះជន្ម ដើម្បីសម្រេចនូវក្តីសុបិនកម្ពុជា។

ក្តីសុបិនកម្ពុជា គឺមិនមែនជាកម្មសិទ្ធិឬការបង្កើតឡើងរបស់បុគ្គលណាម្នាក់នោះទេ ប៉ុន្តែផ្ទុយទៅវិញនេះគឺជាក្តីសង្ឃឹម ការបួងសួង និងចក្ខុវិស័យដ៏ថ្លៃថ្លារួមគ្នារបស់ប្រជាជនកម្ពុជា ដែលបានបង្កើតដួងព្រលឹងជាតិនាអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។ ក្នុងនាមជាអ្នកតំណាង និងជាអ្នកមើលថែរក្សាប្រជាជាតិកម្ពុជា ព្រះរាជវង្សានុវង្សបានអមដំណើរ



នៅព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមប្រតិភូប្រវត្តិសាស្ត្រយោធាចំនួន២០រូប មកពីក្រសួងការពារជាតិ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវសាងសង់វិមានឈ្នះ ឈ្នះ មកទស្សនកិច្ច «ពិព័រណ៍សុបិនកម្ពុជា» ដោយមានការទទួលស្វាគមន៍ ពីឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ជែលដ្រេស (Julio A. Jeldres) អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមប្រតិភូប្រវត្តិសាស្ត្រយោធាចំនួន២០រូប មកពីក្រសួងការពារជាតិ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវសាងសង់វិមានឈ្នះ ឈ្នះ មកទស្សនកិច្ច «ពិព័រណ៌សុបិនកម្ពុជា» ដោយមានការទទួលស្វាគមន៍ ពីឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ជែលដ្រេស (JULIO A. JELDRES) អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តម សីហនុ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ប្រជាជនកម្ពុជា ក្នុងដំណើរឆ្ពោះទៅកាន់ ក្តីសុបិនដែលបន្តចម្រើនទៅមុខនេះ។

បណ្ណាល័យសម្តេចម៉ែ មានកិត្តិយសសូមរំឭកអំពីដំណើរនេះ តាមរយៈពិព័រណ៍រូបថត ពីព្រោះថា អនាគតរបស់កម្ពុជា គឺមិនត្រឹមតែពឹងផ្អែកទៅលើការបន្តជំនឿទៅលើក្តីសុបិនកម្ពុជាប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ពឹងផ្អែកទៅលើការយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់មនុស្សជំនាន់មុនដែលពលីជីវិតរបស់ខ្លួនដើម្បីសម្រេចក្តីសុបិន។

ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ជែលដ្រេស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្តេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុ ទទួលស្វាគមន៍ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ និងក្រុមប្រតិភូដោយមានបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងជាអ្នកសម្របសម្រួល និងបកប្រែ។ នៅក្នុងឱកាសនោះ ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ជែលដ្រេស បង្ហាញដល់ប្រភូអំពីខ្លឹមសារនៃពិព័រណ៍ដែលបែងចែកទៅតាមផ្នែកដូចខាងក្រោម ៖

**ទស្សនីយភាពទី ១** — គឺជាពិព័រណ៍នៃរូបភាព

ចំនួន ១៨ ផ្ទាំង ឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍សំខាន់ៗ សមិទ្ធផល និងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ដែលកំណត់នូវសាវតារនៃរាជវង្សានុវង្ស ចាប់តាំងពីការឡើងគ្រងរាជ្យសម្បត្តិរបស់សម្ដេចព្រះបរមរតនកោដ្ឋកាលពីឆ្នាំ១៩៤១រហូតដល់ការឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះបរមនាថ ព្រះបាទ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០០៤។ ពិព័រណ៍នេះ រួមបញ្ចូលរូបថតដែលមិនអាចកាត់ថ្លៃបាន ដោយភ្ជាប់មកនូវចំណងជើងពិពណ៌នាជាភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងវីដេអូឯកសាររយៈពេលដប់បួននាទី ដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រនេះ រួមជាមួយនឹងសេចក្ដីអធិប្បាយជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ទស្សនីយភាពទី ២** — គឺជាពិព័រណ៍ពហុសណ្ឋានបង្ហាញនៅលើតុឈើចំនួនប្រាំ និងក្ដារខៀនមួយ ដែលសំយោគគំនិតចេញពីក្ដារឆ្នួន និងតុរបស់សិស្សសាលាបឋមសិក្សាកាលពីទសវត្សរ៍ឆ្នាំ១៩៦០។ ពិព័រណ៍នេះ គឺជាការតំណាងបែបសិល្បៈនៃការប្ដេជ្ញាចិត្តរបស់ព្រះរាជវង្សានុវង្ស និងប្រជាជនកម្ពុជាចំពោះវិស័យអប់រំ និងជាការតាំងបង្ហាញលើឧបករណ៍ពហុមុខងារដែលផ្ដល់ឱកាសឲ្យទស្សនិកជនធ្វើអន្តរកម្ម ក្នុងគោលបំណងជំរុញទឹកចិត្តដល់យុវជនកម្ពុជាឲ្យមានក្ដីស្រមៃមុតមាំនៅក្នុងការបន្តការសិក្សាកម្រិតឧត្ដមសិក្សា។ ពិព័រណ៍នេះ មានតាំងបង្ហាញឯកសារជាប្រភេទរូបភាព និងសោត-ទស្សន៍ដែលរួមមានដូចជា តន្ត្រី, សំឡេង, និងឈុតភាពយន្តខ្លីៗ, ព្រមទាំងទស្សនាវដ្ដី និងសៀវភៅបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០។ ការតាំងបង្ហាញនេះ គឺជាពិព័រណ៍ចល័ត ដែលនឹងត្រូវដាក់តាំងនៅតាមសាលារៀនដែលបានជ្រើសរើស នៅក្នុងខេត្តទាំងអស់ទូទាំងប្រទេសកម្ពុជា។

**ទស្សនីយភាពទី ៣** — គឺជាការតាំងបង្ហាញរូបថតចម្រុះដ៏ប្រណីតចំនួន ២៥ ផ្ទាំង ដែលបង្ហាញឲ្យឃើញពីព្រះរាជដំណើររបស់សម្ដេចឪ និងសម្ដេចម៉ែ ក្នុងផ្នែកប្រវត្តិសាស្ត្រ និងផ្នែកនយោបាយ។

នៅចុងបញ្ចប់នៃទស្សនកិច្ច ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រេស (Julio A. Jeldres) ជូនសៀវភៅដែលមានចំណងជាថា «នរោត្តម សីហនុ និង ជូ អេនឡាយ៖ មិត្តភាពដ៏កម្រនៅក្នុងអំឡុងនៃការរីកសាយភាយរបស់សង្គ្រាមត្រជាក់» ដល់ឯកឧត្ដម នាយឧត្ដមសេនីយ៍ ណឹម សុវត្ថិ។ ឯកឧត្ដម នាយឧត្ដមសេនីយ៍ ណឹម សុវត្ថិ សម្ដែងនូវការអរគុណ និងបង្ហាញនូវការពេញចិត្តជាមួយនឹងអត្ថន័យនៃពិព័រណ៍ «សុបិនកម្ពុជា» ជាពិសេស គឺការរៀបចំពិព័រណ៍ដែលមានភាពទាក់ទាញ។





នៅព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រុមប្រតិភូប្រវត្តិសាស្ត្រយោធាចំនួន២០រូប មកពីក្រសួងការពារជាតិ ដឹកនាំដោយ ឯកឧត្ដម នាយឧត្ដមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយកអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវសាងសង់វិមានឈ្នះ ឈ្នះ មកទស្សនកិច្ច «ពិព័រណ៍សុបិនកម្ពុជា» ដោយមានការទទួលស្វាគមន៍ ពីឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រេស (Julio A. Jeldres) អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ សម្ដេចព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សូមប្រកាសរកសមាជិកគ្រួសារដែលបែកគ្នា



សឹប ផាត សព្វថ្ងៃរស់នៅភូមិអូរតាប្រុក ឃុំអូរសណ្ដាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាងខ្ញុំឈ្មោះ សឹប ផាត ភេទស្រី អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិអូរតាប្រុក ឃុំអូរសណ្ដាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ សូមប្រកាសស្វែងរកក្រុមគ្រួសាររបស់ខ្ញុំដែលបែកគ្នានៅក្នុងឆ្នាំ១៩៧៥ រួមមាន១) ឪពុកឈ្មោះ សឹប ខឿន មានអាយុប្រហែលជា៥០ឆ្នាំ (ក្នុងឆ្នាំ១៩៧៥) ២) ម្ដាយឈ្មោះ ស៊ុក ផេម មានអាយុបងឪពុករបស់ខ្ញុំមួយឆ្នាំ ៣) ប្អូនប្រុសឈ្មោះ ខឿន ភឿន អាយុប្រហែល៨ឆ្នាំ ៤) ប្អូនស្រីឈ្មោះ ខឿន សាវឿន អាយុ៣ឆ្នាំ ៥) ម្ដាយចុងឈ្មោះ ឈូក អាយុប្រហែលជា៥០ឆ្នាំ និង ៦) កូនប្រុសរបស់គាត់ឈ្មោះ ខឿន យាង អាយុ៧ឆ្នាំ ។

យើងបានបែកគ្នានៅពេលដែលអង្គការចាប់ឪពុករបស់ខ្ញុំយកទៅដាក់នៅមន្ទីរឃុំឃាំង ខាងលិចត្រាចក្រោល ព្រោះឪពុករបស់ខ្ញុំធ្លាប់ធ្វើជាមេ៥០ខ្នង នៅក្នុងរបប លន់ នល់។ នៅក្នុងឆ្នាំ១៩៧៨ គណៈសហករណ៍ដែលស្រឡាញ់ចូលចិត្តខ្ញុំបានមកប្រាប់ខ្ញុំថា «មី ផាត អើយ ម្ដាយ មីផាត ឯងអង្គការឲ្យនៅមើលគោ និងដាំបាយ, ម្ដាយចុងឯងនៅមន្ទីរឃុំឃាំង ចំណែកឪពុកឯងអង្គការចាត់តាំងឲ្យធ្វើរទេះ និងធ្វើកីតម្បាញនៅសហករណ៍អូរតាប្រុក។ នៅពេលរដូវច្រូតស្រូវ ខ្ញុំទៅយកឪពុក មីផាតឯង មកសហករណ៍យើងវិញ»។ ប៉ុន្តែមិនទាន់បានច្រូតផងកងទ័ពវៀតណាមបានវាយចូលមក ក៏បាត់ដំណឹងពួកគាត់រហូត។

នៅក្នុងឆ្នាំ១៩៨០ មានសំបុត្រមួយផ្ញើតាមឡានពីបារាយណ៍ទឹកថ្លាមកដាក់នៅឃុំអូរសណ្ដាន់។ ពេលនោះ សេនាជនឃុំអូរសណ្ដាន់បានយកសំបុត្រនោះមកបង្ហាញខ្ញុំដែលនៅខ្នងសំបុត្រ សរសេរភូមិអូរតាប្រុក ឃុំអូរសណ្ដាន់ ប៉ុន្តែបែរជាដាក់ចំណងជើងខុសថា «ពីម្ដាយឈ្មោះ ភីនឹករឭកកូន» ទៅវិញ ដែលឈ្មោះ ភីនេះត្រូវជាប្អូនស្រីរបស់ខ្ញុំ និងកំពុងរស់នៅជាមួយខ្ញុំ។ សេនាជននោះថែមទាំងបាននិយាយថា ទាល់តែឲ្យមាសគាត់មួយជី ទើបគាត់ឲ្យហែកសំបុត្រនោះអាន។ ដោយសារតែខ្ញុំក្រមិនមានប្រាក់ឲ្យ ទើបសេនាជននោះផ្ញើសំបុត្រទៅម្ចាស់គេវិញ ហើយចាប់តាំងពីនោះមកខ្ញុំបាត់ដំណឹងក្រុមគ្រួសាររបស់ខ្ញុំរហូតមកដល់សព្វថ្ងៃ។ ខ្ញុំគិតថាសំបុត្រដែលផ្ញើមកនោះគឺឪពុករបស់ខ្ញុំគឺជាអ្នកសរសេរផ្ញើមក ប៉ុន្តែគាត់សរសេរច្រឡំឈ្មោះ។ ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារចំណែកប្អូនៗស្រីរបស់ខ្ញុំឈ្មោះ ខឿន ភី និង ខឿន សើង បានស្លាប់កាលពី៥ឆ្នាំមុន។ ប្រសិនបើ បងប្អូនណាបានស្គាល់ឈ្មោះដូចខ្ញុំរៀបរាប់ខាងលើ សូមទាក់ទងមកនាងខ្ញុំតាមរយៈលេខទូរសព្ទ ០៦៧ ៣១៦ ៤១៣។

សូមអរគុណ!

**ជារ៉ាវដ្ឋ មេត្តា**

# បងប្អូនខ្ញុំចំនួន៤នាក់ដែលចូលធ្វើបដិវត្តន៍ខ្មែរក្រហម



ហ៊ឹម យ៉ុង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហ៊ឹម តន ភេទស្រី អាយុ៦៣ឆ្នាំ ក្នុងឆ្នាំ២០០៥ រស់នៅភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ហ៊ឹម ឡុក និងម្តាយឈ្មោះ ខៀវ បាន់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់។ ខ្ញុំមានប្តីឈ្មោះ សំ ឡូត និងមានកូនម្នាក់ឈ្មោះ ពៅ ចាន់ត្រា។ ខាងក្រោមនេះគឺជារឿងរ៉ាវអំពីបងប្អូនរបស់ខ្ញុំដែលបានបាត់ខ្លួនបន្ទាប់ពីចូលបដិវត្តន៍ខ្មែរក្រហម ៖

ប្អូនទី៤របស់ខ្ញុំឈ្មោះ ហ៊ឹម យ៉ុង ភេទស្រី បានចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៧០។ កាលពីក្មេងយ៉ុងបានរៀនសូត្ររយៈពេលតែពីរឆ្នាំតែប៉ុណ្ណោះ ព្រោះប្រទេសជាតិកើតមានសង្គ្រាមនៅឆ្នាំ១៩៧០។ បន្ទាប់ពីឈប់រៀនប្អូនរបស់ខ្ញុំបានមករស់នៅជួបជុំគ្រួសារក្នុងភូមិអង្គរស និងជួយធ្វើស្រែចម្ការឪពុកម្តាយរបស់ខ្ញុំវិញ។ នៅឆ្នាំ១៩៧១ ឈ្មោះ សុខ ប៊ុតចំរើន ដែលធ្វើការជាមួយក្រុមរណសិរ្សនៅតំបន់ ២៥ និងសមាជិកប្រមាណចំនួន១០នាក់ បានមកផ្សព្វផ្សាយ និងជ្រើសរើសប្រជាជននៅក្នុងភូមិអង្គរសឲ្យចូលរួមធ្វើបដិវត្តន៍។ សុខ ប៊ុតចំរើន ចូលមកធ្វើការនៅក្នុងភូមិអង្គរសបានដោយមានការជួយសម្របសម្រួលពីមេភូមិ និងមេឃុំអង្គរស។

អំឡុងពេល សុខ ប៊ុតចំរើន ចូលមកផ្សព្វផ្សាយប្អូនរបស់ខ្ញុំឈ្មោះ ហ៊ឹម យ៉ុង រួមនឹងប្រជាជនចំនួន១១នាក់ផ្សេងទៀត បានស្ម័គ្រចិត្តចូលរួមជាមួយបដិវត្តន៍ ។ នៅពេលចូលធ្វើបដិវត្តន៍ ដំបូងនារីៗចូលធ្វើជាពេទ្យ ចំណែកប្រុសៗចូលធ្វើយោធា។ បន្ទាប់ពីប្អូនរបស់ខ្ញុំចូលបដិវត្តន៍បានរយៈពេល១ឆ្នាំ សុខ ប៊ុតចំរើន បាននាំប្អូនខ្ញុំនិងអ្នកភូមិ១១នាក់ទៀតត្រឡប់មកលេងស្រុក កំណើតនិងជ្រើសរើសអ្នកភូមិចូលធ្វើបដិវត្តន៍បន្ថែមទៀត។ នៅពេលដែលប្អូនរបស់ខ្ញុំឈ្មោះយ៉ុងត្រឡប់ទៅវិញក៏បាននាំប្អូនពៅក្រោះ ២នាក់គឺប្អូនស្រី ហ៊ុម យឿន និងប្អូនប្រុស ហ៊ុម សាវ៉ន ទៅជាមួយដែរ។ នៅក្នុងរបបខ្មែរក្រហម បងប្អូនរបស់ខ្ញុំចំនួន៤នាក់គឺ ទី១) ឈ្មោះ ហ៊ុម យ៉ុង ទី២) ហ៊ុម យឿន ទី៣) ហ៊ុម សាវ៉ន និងទី៤) បងប្រុស ហ៊ឹម សារឿន បានចូលរួមជាមួយបដិវត្តន៍។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះទៅលើរបប លន់ នល់ ទាំងស្រុង។ បន្ទាប់ពីទទួលបានជ័យជម្នះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាតំណាងសមាគមនារីដើម្បីដឹកនាំក្រុមនារីធ្វើការងារ ដូចជា ធ្វើស្រែសាមគ្គី (ក្រុមប្រវាស់ដៃ) និងដាំបន្លែដើម្បីទុកហូបតាមផ្ទះ។ អំឡុងពេលនោះមានប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញជាច្រើនគ្រួសារចូលមករស់នៅជាមួយប្រជាជនក្នុងភូមិអង្គរស។ ប្រជាជនជម្លៀសទាំងនោះធ្វើការងារ និងទទួលរបបអាហារដូចប្រជាជនក្នុងភូមិដែរ។ ចំណែកឯបងសារឿន បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលបានជោគជ័យ គាត់បានត្រឡប់មកផ្ទះវិញ ដែលពេលនោះខ្ញុំឃើញជើងរបស់គាត់ពិការដោយសារត្រូវគ្រាប់អំឡុងពេលសង្គ្រាម។ បងសារឿន បានឡើងតួនាទីគ្រប់គ្រងយោធានៅស្រុកមេសាង ជំនួស

តាជ្រៅ និងតាគល់។ គ្រួសាររបស់ខ្ញុំនៅពេលនោះមិនសូវលំបាកប៉ុន្មានទេ ព្រោះមានបងប្អូនចូលធ្វើបដិវត្តន៍។

នៅឆ្នាំ១៩៧៧ បន្ទាប់ពីមានព្រឹត្តិការណ៍ចោ ទ សោ ភឹម ថាក្បត់ អង្គការបានមកចាប់បង សារឿន យកទៅសម្លាប់ចោល ប៉ុន្តែខ្ញុំមិនបានដឹងថាយកគាត់ទៅសម្លាប់នៅទីណាឡើយ។ ចំណែកប្រពន្ធរបស់បង សារឿន ឈ្មោះ ជី នង និងកូនចំនួន៣នាក់ទៀតអង្គការបានបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង ហើយបាត់ដំណឹងតាំងពីពេលនោះមក។ ចំណែកឪពុកម្តាយ បងប្អូន និងក្រុមគ្រួសាររបស់ខ្ញុំ ក៏អង្គការបញ្ជូនទៅតំបន់ដីខ្លាញ់នៅខេត្តពោធិ៍សាត់ដែរ។ អង្គការបានប្រាប់គ្រួសាររបស់ខ្ញុំថា នៅ ទីនោះមានអាហារហូបគ្រប់គ្រាន់ ហើយការរស់នៅងាយស្រួលជាងនៅភូមិអង្គរស ប៉ុន្តែការពិតគឺធ្វើការងារលំបាកជាងមុនហើយការហូបចុកកាន់តែតិចទៅៗ។

ខ្ញុំនិងក្រុមគ្រួសារបានទៅរស់នៅសហករណ៍ចាហ៊ួយ ស្ថិតនៅក្នុងភូមិបឹងផុង ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ការងាររបស់ខ្ញុំគឺដើររើសគួរស្រូវ និងលើកប្រព័ន្ធភ្លឺស្រែ។ នៅ ទីនោះខ្ញុំបានជួបប្អូនស្រីឈ្មោះ ហ៊ឹម យឿន ហើយបម្រុងនាំនាងមកជួបឪពុករបស់ខ្ញុំវិញ ប៉ុន្តែប្អូន យឿន ប្រាប់ខ្ញុំថារវល់ការងារមិនបានមកជាមួយខ្ញុំទេ។ ឪពុករបស់ខ្ញុំខកបំណងយ៉ាងខ្លាំង ព្រោះមិនបានជួបកូនស្រីពៅរបស់គាត់ ធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺ ហើយក្រោយមកក៏ស្លាប់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងក្រុមគ្រួសារបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ ហើយចាប់ផ្តើមធ្វើស្រែចិញ្ចឹមជីវិតបន្ត។ រយៈពេលពីរឆ្នាំក្រោយមក ម្តាយរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺហើយស្លាប់ ចំណែកប្អូនរបស់ខ្ញុំទាំងអស់ដែលចូលរួមជាមួយខ្មែរក្រហមក៏ស្លាប់និងបាត់ខ្លួនទៀត។ ទោះបីយ៉ាងណាខ្ញុំនៅតែមានសេចក្តីសង្ឃឹមថាប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតនៅឡើយ។

**ភា រស្មី**


K00665
TSL 4263
554

ប្រវត្តិរូប ហ៊ឹម យ៉ុង ពេលចូលរួមជាមួយបដិវត្តន៍។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

សម្ដេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ យាងចូលរួមព្រះរាជពិធីបុណ្យឯករាជ្យជាតិ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៦៩។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

សម្ដេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និងសម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 275, November 2022 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.